# مدرسة اهل البيت

# សាលា
# អាស់លុល-បៃត៍

## សៀវភៅ ហ្វីកោ្ហះហ៍ ថ្នាក់ទី ៧ (អាយុ ១១-១២ ឆ្នាំ)

រ៉ស៊ូលុលឡោះហ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - ស្វ៏ឡាត៉់ - សាច៉់ដ្វាស៉់(១) ........................................ ៤
មេរៀនទី ២ - ស្វ៏ឡាត៉់ - សាច៉់ដ្វាស៉់(២) ........................................ ៧
មេរៀនទី ៣ - ស្វ៏ឡាត៉់ - សាច៉់ដ្វាស៉់ (៣) ........................................ ៩
មេរៀនទី ៤ - ស្វ៏ឡាត៉់ - តាស្ហ៊ាស់ហ្វ៊ូដ្វ និង សាឡាម ........................................ ១១
មេរៀនទី ៥ - ស្វ៏ឡាត៉់ - តារទិប, មូវ៉ាឡាត់ និង តាក៉ុគ្វីបាត់ ........................................ ១៥
មេរៀនទី ៦ - ស្វ៏ឡាត៉់ - មូណាហ្វីយ៉ាត់ក្នុងស្វ៏ឡាត៉់ ........................................ ១៧
មេរៀនទី ៧ - ស្វ៏ឡាត៉់ - ម៉ាសាអ៊ីល (مسائل បញ្ហា) នានា (១) ........................................ ២០
មេរៀនទី ៨ - ស្វ៏ឡាត៉់ - ម៉ាសាអ៊ីល(ច្បាប់)នានា(២) ........................................ ២៣
មេរៀនទី ៩ - ស្វ៏ឡាត៉់ - កន្លែងស្វ៏ឡាត៉់ ........................................ ២៧
មេរៀនទី ១០ - ស្វ៏ឡាត៉់ - សំលៀកបំពាក់សម្រាប់ស្វ៏ឡាត៉់ ........................................ ៣០
មេរៀនទី ១១ - ស្វ៏ឡាត៉់ - ពេលវេលាស្វ៏ឡាត៉់ ........................................ ៣៣
មេរៀនទី ១២ - ស្វៅម៍(១) ........................................ ៣៦
មេរៀនទី ១៣ - ស្វៅម៍(២) ........................................ ៣៨
មេរៀនទី ១៤ - អាំរ៍ ប៊ិល-ម៉ាក៉ុរូហ្វ (امر بالمعروف) ........................................ ៤១
មេរៀនទី ១៥ - ណាហ្វ៊ី អ៊ុនិល មុនការ (نهى عن المنكر) ........................................ ៤៣
មេរៀនទី ១៦ - តាវ៉ាល់ឡា (تولّى) ........................................ ៤៥
មេរៀនទី ១៧ - តាបារ៉ (تبرأ) ........................................ ៤៧
លំហាត់ ១ ........................................ ៤៨
លំហាត់ ២ ........................................ ៥១
លំហាត់ ៣ ........................................ ៥២
លំហាត់ ៤ ........................................ ៥២
លំហាត់ ៥ ........................................ ៥៣
លំហាត់ ៦ ........................................ ៥៤
លំហាត់ ៧ ........................................ ៥៤
លំហាត់ ៨ ........................................ ៥៥
លំហាត់ ៩ ........................................ ៥៦
លំហាត់ ១០ ........................................ ៥៧

**មេរៀនទី ១**

# ស្វ៊ូទឡាត់ - អធិប្បាយលំអិតអំពីទង្វើវ៉ាយ៊ីបក្នុងស្វ៊ូទឡាត់

## សាច់ដ្ងាស់

សាច់ដ្ងាស់ពីរក្នុងរ៉ក់អាត់នីមួយៗជាវ៉ាយ៊ីបរបស់ស្វ៊ូទឡាត់ ។ សាច់ដ្ងាស់ទាំងពីររួមជាវ៉ាយ៊ីប រុកន៍ (រូកុនវ៉ាយ៊ីប) ក្នុងស្វ៊ូទឡាត់ ។ បើភ្លេចសាច់ដ្ងាស់ទាំងពីរ ឬបើថែមសាច់ដ្ងាស់ពីរ ទោះបីដោយចេតនាក្ដី ដោយអចេតនាក្ដី ស្វ៊ូទឡាត់ត្រូវមោឃៈ (បាទិ្វល) ។

តែបើភ្លេចសាច់ដ្ងាស់មួយ ឬបើថែមសាច់ដ្ងាស់មួយដោយភ្លាំងភ្លាត់ ស្វ៊ូទឡាត់នៅតែត្រឹមត្រូវ ។ ប្រាកដណាស់ បើថែមឬកាត់បន្ថយសាច់ដ្ងាស់មួយដោយចេតនា ស្វ៊ូទឡាត់ត្រូវមោឃៈ ។

ប្រាំមួយប្រការវ៉ាយ៊ីបក្នុងសាច់ដ្ងាស់៖

១. ក្នុងពេលសាច់ដ្ងាស់ ប្រាំពីរប៉ែករបស់រូបកាយចាំបាច់ត្រូវប៉ះដី (កម្រាល) ។ ប៉ែករូបកាយនោះគឺ៖ ថ្ងាស, បាតដៃទាំងពីរ, ជង្គង់ទាំងពីរ, មេជើងរបស់ជើងទាំងពីរ ។ ក្នុងចំណោមប៉ែកទាំងប្រាំពីរនេះ ចាំបាច់ត្រូវដាក់ថ្ងាសផ្ទាល់ដី ។

២. ស៊ីក៌ (ការសូត្រ) ក៏ជាវ៉ាយ៊ីបរបស់សាច់ដ្ងាស់ដែរ ។ ស៊ីក៌របស់សាច់ដ្ងាស់ស្រដៀងស៊ីក៌រ៉ូគុអ៊ុំដែរ ខុសគ្នាតែមួយពាក្យទេ ។ គឺសូត្រដូចតទៅគឺ៖ "ស៊ុបហ្ហាណា រ៉ប់ប៊ីយ៉ាល់ អាគ់ឡា វ៉ា ប៊ីហ្ហាំឌិះហ្វ៍ (سُبْحَانَ رَبِّيَ الْأَعْلَىٰ وَ بِحَمْدِهِ)

៣. ត្រូវឲ្យនឹងខ្លួនក្នុងពេលសូត្រស៊ីក៌ ។

៤. ប៉ែករូបកាយទាំងប្រាំពីរប៉ែកចាំបាច់ត្រូវប៉ះដី (កម្រាល) ក្នុងពេលសូត្រ ។

ប្រសិនបើអ្នកចាំបាច់ត្រូវលើកប៉ែកណាមួយពីដី អ្នកត្រូវស្ងាត់មាត់ (គឺឈប់សូត្រសិន) ក្រោយមកបានដាក់ប៉ែកនោះមកលើដីវិញទើបអ្នកសូត្រតទៀត ។

៥. បន្ទាប់ពីសាច់ដ្ហាស់ទីមួយ ត្រូវងើបមកអង្គុយ ។

៦. កន្លែងដែលគេដាក់ថ្ងាសនិងជើងត្រូវឲ្យស្មើគ្នា ។ ប្រសិនបើមានកម្ពស់ខុសគ្នាឲ្យខុសគ្នាតិចជាង ១០ សង់ទីម៉ែត្រ ។

## សាច់ដ្ហាស់ជាប៉ែកមួយដែលថ្លៃថ្នូរជាងគេរបស់ស្វឡាត់

### ច្បាប់ (ហ៊ុកុម) ផ្សេងទៀតពាក់ព័ន្ធនឹងសាច់ដ្ហាស់

១. បើអ្នកណាមិនអាចធ្វើសាច់ដ្ហាស់ឲ្យបានត្រឹមត្រូវទេ ដោយសារមានជម្ងឺ ឬដោយសារមូលហេតុផ្សេងទៀត ឲ្យអ្នកនោះធ្វើដូចតទៅនេះ (គប្បីធ្វើតាមលំដាប់) គឺ៖

ក) ព្យាយាមបង្អោនខ្លួនតាមសមត្ថភាពដែលអាចធ្វើទៅបាន ហើយលើកដុំដីម៉ុស្ហ៍ (مهر) ឬទួរបាស់ (تربة) មករកថ្ងាស ។
ខ) ធ្វើសាច់ដ្ហាស់ដោយឱនក្បាល ។
គ) ធ្វើសាច់ដ្ហាស់ដោយបិទត្របកភ្នែក ។

ប្រសិនបើមិនអាចធ្វើកាយវិការទាំងនេះបានទេ ត្រូវធ្វើសាច់ដ្ហាស់ដោយកាយវិការដៃ ឬ ដោយប៉ែករូបកាយមួយផ្សេងទៀត ។

២. ប្រសិនបើមានរបួសលើថ្ងាស មិនអាចដាក់ថ្ងាសលើដីបានទេ ឲ្យធ្វើសាច់ដ្ហាស់ជាមួយប៉ែកមួយទៀតរបស់ថ្ងាស ។ ប្រសិនបើមានរបួសពេញថ្ងាសតែម្តង ឲ្យធ្វើសាច់ដ្ហាស់ជាមួយចិញ្ចើម ។

៣. ប្រសិនបើអ្នកណាភ្លេចធ្វើសាច់ដ្ហាស់ ហើយនឹកឃើញវិញមុនធ្វើរុគុអ៍ខាងមុខ ឲ្យអ្នកនោះអង្គុយចុះវិញហើយធ្វើសាច់ដ្ហាស់ រួចហើយបំពេញស្វឡាត់បន្ត ។ តែបើនឹកឃើញវិញក្រោយពីបានរុគុអ៍ហើយ ស្វឡាត់អ្នកនោះត្រូវមោឃៈ ។

៤. ប្រសិនបើអ្នកណាដាក់ថ្ងាសលើអ្វីមួយ ដែលច្បាប់បានហាមធ្វើសាច់ដ្ហាស់លើ ឲ្យអ្នកនោះលើកថ្ងាសទៅដាក់លើអ្វីមួយដែលច្បាប់អនុញ្ញាត ។

៥. ប្រសិនបើអ្នកណាដាក់ថ្ងាសលើកន្លែងដែលមានកម្ពស់លើសពី ១០ សង់ទីម៉ែត្រ ប្រៀបធៀបនឹងកន្លែងដាក់ជើង ឲ្យអ្នកនោះលើកក្បាលដើម្បីកែឲ្យកម្ពស់ទាបជាង ១០ សង់ទីម៉ែត្រ ។

៦. អ៊ីស្លាមហាមដាច់ខាតធ្វើសាច់ដ្ហាស់ដាក់អ្នកណាផ្សេងពីអល់ឡោះហ្ជ ។ អ្នកខ្លះដាក់ថ្ងាសលើមាត់ទ្វារមតក(មៈតៈកៈ)ចេតិយរបស់អ៊ីម៉ាំពិសិដ្ឋﷺ ប្រសិនបើសាច់ដ្ហាស់នេះជាសាច់ដ្ហាស់ ស្ហុករ៍ ចំពោះអល់ឡោះហ្ជ វាជាទង្វើត្រឹមត្រូវ ពុំនោះទេវាជាទង្វើហ្រាំ ។

## សាច់ដ្ហាស់ជាមិរ៉ាជ្ជរបស់អ្នកមានសទ្ធា

**មេរៀនទី ២**

# ស្ទ័ទ្បាត់ - អធិប្បាយលំអិតអំពីទង្វើរ៉ាយ៉ីបក្នុងស្ទ័ទ្បាត់

## សាច់ដ្ទាស់

ប្រការ**មុស្តាហ្កាប់** និង ប្រការ**ម៉ាក់រុះហ្ហ័**ក្នុងសាច់ដ្ទាស់ ។

**មុស្តាហ្កាប់** (ស៊ូណាត់)

១. ថាតាក់បៀរមុនសាច់ដ្ទាស់ ពោលគឺ ក្រោយពីថា "សាមីអ៊ុល់ទ្បហ៊្ហ លីម៉ាន់ ហ្កាមីដ្ទាស់" ហើយលើកដៃឡើងពេលថាតាក់បៀរ ។

២. ពេលចុះសាច់ដ្ទាស់ បុរសគប្បីដាក់ប្រអប់ដៃមុនសិន បន្ទាប់មកទើបដាក់ក្បាលជង្គង់ ។ រីឯនារីវិញ គប្បីដាក់ក្បាលជង្គង់មុនដាក់ប្រអប់ដៃ ។

៣. ដាក់ថ្ងាសទៅលើដីឲ្យស៊ប់ ។

៤. ដាក់ក្បាលទាល់តែច្រមុះកកិតដី ។

៥. បុរសគប្បីបន្ទេកដៃពីខ្លួនបន្តិច ។ រីឯនារីគប្បីដាក់ដៃប្របខ្លួន ។ មុស្តាហ្កាប់ឲ្យដាក់ប្រអប់ដៃស្មើត្រចៀក ម្រាមជៀតគ្នា តម្រង់ទៅរកគិ្ឋបទ្បាត់ ។

៦. សម្លឹងមើលទៅឯច្រមុះ ។

៧. សូត្រស៊្មីកសាច់ដ្ទាស់ផ្ទួនគ្នា លើសពីមួយដង ជាចំនួនសេស (បី, ប្រាំ ឬ ប្រាំពីរ) ។

៨. ដាក់ថ្ងាសលើដី ។

៩. នៅលើផ្ទៃដីស្មើពីក្បាលដល់ចុងជើង ។

១០. អង្គុយក្នុងចន្លោះសាច់ដ្ហាស់ទាំងពីរ ។ ក្រោយសាច់ដ្ហាស់ទីពីរអង្គុយដាក់ប្រអប់ជើងឆ្វេងនៅខាងក្រោម ដាក់ខ្នងជើងស្តាំលើបាតជើងឆ្វេង ។

១១. អង្គុយក្នុងចន្លោះសាច់ដ្ហាស់ទាំងពីរ ។ ដាក់ប្រអប់ដៃលើភ្លៅ ។

១២. ក្រោយពីបានងើបពីសាច់ដ្ហាស់ទីមួយ មុសតាហ្ពាប់ឲ្យសូត្រតាក់បៀរ ហើយសូត្រថា "អាស់តាក់ហ្វីរុលឡោះហ្វ រ៉ប់ប៊ី វ៉ា អាទូប៊ូ អ៊ីឡៃហ្ហី (أَسْتَغْفِرُ ٱللَّهَ رَبِّي وَأَتُوبُ إِلَيْهِ)" រួចហើយថាតាក់បៀរមុនចុះសាច់ដ្ហាស់លើកទីពីរ ។

១៣. ថាតាក់បៀរក្រោយសាច់ដ្ហាស់លើកទីពីរ ។

១៤. សូត្រស្វ៊ឡាវ៉ាតក្នុងសាច់ដ្ហាស់ ។

១៥. ដើម្បីក្រោកឡើងបំពេញរ៉ក់អាត់បន្ត បុរសគប្បីលើកជង្គង់មុន បន្ទាប់មក ប្រអប់ដៃ ។ រីឯនារីគប្បីដាក់ប្រអប់ដៃលើភ្លៅហើយងើបឡើង ។

## ម៉ាក់រុះហ្វ

១. អង្គុយលើកែងជើងក្នុងចន្លោះសាច់ដ្ហាស់ទាំងពីរ និងក្រោយពីនោះ (ដោយចុចលើម្រាមជើង) ។
២. ដាក់ដៃលើដី (ពោលគឺប្រអប់ដៃដល់កែងដៃ) ។

៣. សូត្រគួរអានក្នុងសាច់ដ្ហាស់ ។

**ទង្វើមុសតាហ្ពាប់ក្នុងសាច់ដ្ហាស់សម្រាប់នារីស្ថិតនៅលើភាពរាបសារម្យទម និងព្រហ្មចរិយភាព**

## មេរៀនទី ៣

# ស្ទ័ទ្បាត់ - អធិប្បាយលំអិតអំពីទង្វើវ៉ាយ៉ិបក្នុងស្ទ័ទ្បាត់

## សាច់ដ្វាស់

### វត្ថុដែលអាចសាច់ដ្វាស់លើបាន

១. វត្ថុដែលអ្នកត្រូវដាក់ថ្វាសលើចាំបាច់ជាវត្ថុខាងក្រោមនេះគឺៈ

ក) ដីធម្មជាតិ ។

ខ) អ្វីៗដែលដុះពីក្នុងដី ដោយមានលក្ខខណ្ឌថាមិនអាចយកមកប្រើជាអាហារបាន ឬ យកមកធ្វើជាក្រណាត់សំពត់បាន ។

គ) អ្វីៗដែលធ្វើអំពីដីសុទ្ធ ឬអំពីវត្ថុដែលដុះពីដី (ដោយមានលក្ខខណ្ឌដូចខាងលើ) ។

២. "ដី" គឺចង់និយាយថាអ្វីដែលគេស្គាល់ថាជាដីធម្មតា ។ មិនរាប់បញ្ចូលរ៉ែ ឬ ត្បូងពេជ្រ ដែលមានតម្លៃដែលយកមកពីអណ្តូងរ៉ែនោះទេ ពីព្រោះវាមិនមែនដី ហើយក៏មិនដុះមកពីដីទេ ។

៣. ដូចបានថៃងនៅខាងលើហើយ គេមិនអាចសាច់ដ្វាស់លើវត្ថុប្រើជាគ្រឿងបរិភោគ ឬជាក្រណាត់សំពត់បានទេ ។ ដូច្នេះគេសាច់ដ្វាស់លើស្លឹកស្វាយបាន តែមិនអាចសាច់ដ្វាស់លើផ្លែស្វាយបានទេ ។ វត្ថុទីមួយជាវត្ថុដែលមិនអាចហូបបាន ឯវត្ថុទីពីរជាផ្លែឈើឆ្ងាញ់ពីសាមួយ ។

៤. គេអាចសាច់ដ្វាស់លើវត្ថុទាំងអស់បានដែលធ្វើអំពីដីសុទ្ធ ដូចជា "មុស្ហរ៍" ដែលស្ទីអ៊ាស្ទប្រើក្នុងស្ទ័ទ្បាត់ ។

៥. គេអាចសាច់ដ្វាស់លើសន្លឹកក្រដាសទទេឬកំណាត់ឈើបាន ព្រោះវាចេញមកពីដើមឈើដែលដុះមកពីដី ។ គេអាចសាច់ដ្វាស់លើសន្លឹកក្រដាសមាន

សំណោរបានដែរ ឲ្យតែសំណោរនោះជាទឹកមឹក (ជ្រាបទៅក្នុងសាច់ក្រដាស់) ហើយមិនមែនទឹកមឹកដែលបង្កជារបាំងរាំងលើសន្លឹកក្រដាសនោះទេ ។

៦. តែវត្ថុសំណព្វសម្រាប់សាច់ដ្វាស់គឺ "ហ្ការម អ៊ីម៉ាំ ហ្ញសែន៍صلوات الله عليه والسلامនៅការបាឡា"។ គេស្គាល់ដីនេះជាដី "ទូរបាទុល ហ្ញសែនីយ៉ាស់"។ ដីនេះជាដីពិសិដ្ឋព្រោះវា ផ្ទុកនូវលោហិតរបស់អស់បុគ្គលដែលបានពលីជីវិតនៅឯដែនដីការបាឡា ។

កាលពីសម័យរ៉ស៊ូលុលឡោះហ៍صلى الله عليه وآله وسلم បុត្រីព្រះអង្គ ប៊ីប៊ីហ្វាទីម៉ាស់سلام الله عليها បានធ្វើតាស់ប៊ិះហ៍(تسبيح)ពីដីផ្នូររបស់ហ្កាដ្ំរ៉ោះត៍(حضرة)ហ្កាំស្ហាស់ ប៊ិន អាប់ឌុលមុត្តលិប ។ ហ្កាដ្ំរ៉ោះត៍ហ្កាំស្ហាស់ជាអគ្គប្រមុខរបស់បុគ្គលដែលបានពលីជីវិតក្នុងសម័យនោះ ។

បើគេប្រើដុំម៉ុស្ហរ៍សម្រាប់សាច់ដ្វាស់ កុំឲ្យដុំម៉ុស្ហរ៍នោះតូចជាងមេដៃ ។
សាច់ដ្វាស់លើភក់ឬដីខ្សាច់មិនអាចយកជាការបានទេ ព្រោះថ្ងាសមិននឹងមាំមួន ។
បើមិនមានវត្ថុដែលគេអនុញ្ញាតឲ្យសាច់ដ្វាស់លើបាននោះទេ គេអាចសាច់ដ្វាស់លើសំលៀកបំពាក់ខ្លួនឯងបាន ។ បើនៅតែមិនមានលទ្ធភាពទៀត គេអាចសាច់ដ្វាស់លើខ្នងដៃបាន ។ គេអាចយកច្បាប់នេះទៅប្រើបាន បើគេមិនអាចដាក់ថ្ងាសបានលើវត្ថុអនុញ្ញាតសម្រាប់សាច់ដ្វាស់ (ដោយមូលហេតុជម្ងឺ ។ល ។) ។

## ដាក់ថ្ងាសអ្នកលើដីដាស់អ្នកឲ្យនឹកឃើញដើមកំណើតនៃការបង្កើតអ្នក

**មេរៀនទី ៤**

# ស្វ៉ូឡាត់ - អធិប្បាយលំអិតអំពីទង្វើវ៉ាយីបក្នុងស្វ៉ូឡាត់

**តាស្ហាស់ហ៊្វូដ**(១)

តាស្ហាស់ហ៊្វូដមានន័យថាប្តេជ្ញាចិត្ត ។ ជាឈ្មោះរបស់អ្វីដែលយើងសូត្រក្រោយសាច់ដ្ហាស់ទាំងពីរ ក្នុងរ៉ក់អាត់ទីពីរនិងរ៉ក់អាត់ចុងក្រោយរបស់ស្វ៉ូឡាត់នីមួយៗ ។

តាស្ហាស់ហ៊្វូដជាវ៉ាយីប កុយ់រ៉ រុកនី (រូកុនវ៉ាយីបអនុលោម) ។ វាជាវ៉ាយីបមួយដងក្នុងស្វ៉ូឡាត់ពីររ៉ក់អាត់ ក្រោយសាច់ដ្ហាស់ទាំងពីររបស់រ៉ក់អាត់ចុងក្រោយបំផុត ។ វាជាវ៉ាយីបពីរដងក្នុងស្វ៉ូឡាត់បីរ៉ក់អាត់ ឬ បួនរ៉ក់អាត់ ក្រោយសាច់ដ្ហាស់ទីពីររបស់រ៉ក់អាត់ទីពីរ និងក្រោយសាច់ដ្ហាស់ចុងក្រោយរបស់រ៉ក់អាត់ចុងក្រោយ ។

តាស្ហាស់ហ៊្វូដមានដូចតទៅនេះគឺ៖

أَشْهَدُ أَنْ لَا إِلَٰهَ إِلَّا ٱللَّهُ وَحْدَهُ لَا شَرِيكَ لَهُ، وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ. ٱللَّٰهُمَّ صَلِّ عَلَىٰ مُحَمَّدٍ وَآلِ مُحَمَّدٍ.

អាស្ហ៉ាហាឌូ អាល់ឡា អ៊ីឡាហា អ៊ីលឡុលឡ៉ហ៊្វ វ៉ាស៊ុដហ៊្វ ឡា ស្ហារីកាឡាស់
វ៉ា អាស្ហ៉ាហាឌូ អាន់ណា មូហាំម៉ាដ្ហាន់ អាប់ឌូហ៊្វ វ៉ា រ៉ស៊ូលុះហ៍
អល់ឡ៉ហ៊ុមម៉ា ស្វល់លី អាឡា មូហាំម៉ាដ៉ឌីវ វ៉ា អាលី មូហាំម៉ាដ៉

**មានប្រាំប្រការវ៉ាយីបក្នុងតាស្ហាស់ហ៊្វូដ**

១. ត្រូវអង្គុយសូត្រ ។
២. ត្រូវឲ្យនឹងខ្លួនក្នុងពេលសូត្រ ។
៣. ត្រូវសូត្រជាភាសាអារ៉ាប់ ។
៤. មូវ៉ាឡាត់ - គឺត្រូវគោរពនិរន្តរភាព (កុំដាច់) ក្នុងពេលសូត្រ ។

៥. ត្រូវសូត្រដូចខាងលើនេះ ។

## តាស្ហាស់ហ៊្វូដជាសេចក្តីសង្ខេបរបស់ជំនឿយើង

**តាស្ហាស់ហ៊្វូដ(២)**

ទង្វើខាងក្រោមនេះជាមុសតាហ្វាប់ក្នុងតាស្ហាស់ហ៊្វូដ ។

**មុសតាហ្វាប់**

១. ថា "អាល់ហ្វាំឌូ លិលឡាស់" (សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ្ស៍) ឬថា "ប៊ិសមិលឡាហ៊ី វ៉ាប៊ិលឡាហ៊ី វាល់-ហ្វាំឌូ លិលឡាស់ វ៉ា ខយ់រុល អាស់ម៉ាអ៊ី លិលឡាស់ (بسم الله وبالله والحمد لله وخير الاسماء لله ដោយព្រះនាមអល់ឡោះហ្វ៍ ដោយអាស្រ័យលើអល់ឡោះហ្វ៍ សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ្វ៍ ព្រះនាមដ៏ឧត្តុង្គឧត្តមជាព្រះកម្មសិទ្ធិរបស់ព្រះអង្គ) មុនចាប់ផ្តើមសូត្រតាស្ហាស់ហ៊្វូដ ។

២. ដាក់ប្រអប់ដៃលើភ្លៅ ម្រាមជៀតគ្នា ។

៣. សម្លឹងមើលទៅឯម៉ុស្វរ៍ ឬ ក្បាលជង្គង់ ។

៤. ក្រោយតាស្ហាស់ហ៊្វូដទីមួយ មុសតាហ្វាប់ឲ្យថា "វ៉ា តាកូប់បាល់ ស្ហាហ្វាអ៊ុតាហ៊ូ វ៉ារហ្វាក់ ដ្ហារ៉យ៉ាតាស់ (و تقبل شفاعته وارفع درجته សូមព្រះអង្គព្រមទទួលការជួយធ្វើអន្តរាគមន៍របស់ព្រះសាស្តាឲ្យអស់ទូលព្រះបង្គំជាខ្ញុំនាថ្ងៃជំនុំជម្រះ ហើយសូមព្រះអង្គលើកតម្កើងឋានន្តរស័ក្តិឲ្យព្រះអង្គផង) ។

៥. ក្រោយតាស្ហាស់ហ៊្វូដទីពីរ មុសតាហ្វាប់ឲ្យថា "ស៊ុបហ្វាណល់ឡោះហ្វ៍" (សូម

ថ្វាយសេចក្តីរុងរឿងចំពោះអល់ឡោះហ៍) ។

## ស្វឡាតក្នុងតាស្ហាស់ហ៊ូដ្ឋនះបញ្ជាំងឲ្យឃើញថាមូហាំម៉ាដ់ﷺ និងអាស់លុល-បៃត៍ព្រះអង្គមិនអាចញែកចេញបានពីស្វឡាត់ទេ

**សាឡាម**

សាឡាមជារ៉ាឃ៊ីបចុងក្រោយរបស់ស្វឡាត់ ។ ជារ៉ាឃ៊ីបកុយរ៉ រុកនី (រូកុនរ៉ាឃ៊ីប អនុលោម) ។ សាឡាមជារ៉ាឃ៊ីបក្រោយតាស្ហាស់ហ៊ូដ្ឋក្នុងរ៉ក់អាត់ចុងក្រោយ ។

សាឡាមវ៉ាឃ៊ីបមានដូចតទៅគឺ ៖

**អាស់សាឡាមូ អាឡៃណា វ៉ា អាឡា អ៊ីបាឌិលឡាហ៊ីស្វស្វលីហ៊ីន**

ឬ

**អាស់សាឡាមូ អាឡៃគុម វ៉ា រ៉ោះហ៍ម៉ាទុលឡហ៊ី វ៉ា បារ៉កាទុះហ៍**

ទង្វើខាងក្រោមនេះជារ៉ាឃ៊ីបក្នុងសាឡាម គឺ៖

១. សូត្រឃ្លាណាមួយក្នុងចំណោមឃ្លាទាំងពីរខាងលើនេះ ។

២. ចាំបាច់ត្រូវសូត្រជាភាសាអារ៉ាប់ ។

៣. ចាំបាច់ត្រូវអង្គុយក្នុងពេលសូត្រ ។

៤. ចាំបាច់ត្រូវនៅស្ងៀមក្នុងពេលសូត្រ ។

សាឡាមជាទីបញ្ចប់របស់ស្វឡាត់ ។

អ្វីៗដែលហ្ារ៉ាំ (ត្រូវហាម) ក្រោយ "តាក់ប៊ីរ៉ទុល អ៊ិះហ្ររ៉ម" ទៅជាហ្ាឡាល់ (អនុញ្ញាត) វិញ ក្រោយសាឡាមរួច ។

ទង្វើមុសតាហ្ាប់ក្នុងសាឡាមមានៈ

១. ការអង្គុយចាំបាច់ត្រូវឲ្យដូច ដែលបានរៀនរួចមកហើយក្នុងមេរៀនសាច់ដ្ហាស់ (យ៉ូលុស) ។
២. សូត្រសាឡាមទាំងពីរខាងលើនេះ ។
៣. សូត្រឃ្លាខាងក្រោមនេះមុនសាឡាមទាំងពីរខាងលើនេះ គឺៈ

**"អាស់សាឡាមូ អាុឡៃកា អៃយូហ្ាន់ ណាប៊ីយូ វ៉ា រ៉ោះហ្ម៉ាទុលឡ៉ហ្ុី វ៉ា បារ៉កាទុះហ៍**
(សូមឲ្យសិរីសួស្តី (របស់អល់ឡោះហ្វ) កើតមានដល់ព្រះអង្គ ឱបណ្តាសាស្តាអឺយ ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ្វ និងពរជ័យរបស់ព្រះអង្គ) ។

៤. សូត្រតាក់បៀរបីដងក្រោយសាឡាម ។

**សាឡាមជាការរំលឹកនូវភាតរភាពក្នុងសាសនាអ៊ីស្លាម**

**មេរៀនទី ៥**

# ស្វ៍ឡាត់ - អធិប្បាយលំអិតអំពីទង្វើរ៉ាឃ្វិបក្នុងស្វ៍ឡាត់

**តារទិប និង មូវ៉ាឡាត់**

តារទិបនិងមូវ៉ាឡាត់ជាទង្វើរ៉ាឃ្វិបមួយប៉ែករបស់ស្វ៍ឡាត់ ។

តារទិបមានន័យថាលំដាប់ត្រឹមត្រូវរបស់ទង្វើនានា ។
មូវ៉ាឡាត់មានន័យថាភាពរលូនជានិរន្តរភាពក្នុងស្វ៍ឡាត់ ។

ប៉ែកនីមួយៗរបស់ស្វ៍ឡាត់ចាំបាច់ត្រូវប្រតិបត្តទៅតាមលំដាប់ ដែលច្បាប់បានចែងមក ។

ប្រសិនបើគេផ្លាស់ប្តូរលំដាប់របស់ប៉ែករ៉ាឃ្វិប រុកន៍ (រូកុនរ៉ាឃ្វិប) របស់ស្វ៍ឡាត់ដោយចេតនា ឬ ដោយអចេតនា ស្វ៍ឡាត់ត្រូវមោឃៈ ។

ប្រសិនបើគេផ្លាស់ប្តូរលំដាប់របស់ប៉ែករ៉ាឃ្វិប កុយ់រ៉ុ រុកនី (រូកុនរ៉ាឃ្វិបអនុលោម) របស់ស្វ៍ឡាត់ដោយចេតនា ស្វ៍ឡាត់ត្រូវមោឃៈដែរ ។

ក៏ប៉ុន្តែ ប្រសិនបើគេផ្លាស់ប្តូរលំដាប់របស់ប៉ែករ៉ាឃ្វិប កុយ់រ៉ុ រុកនី (រូកុនរ៉ាឃ្វិបអនុលោម) របស់ស្វ៍ឡាត់ដោយអចេតនា ស្វ៍ឡាត់មិនមោឃៈទេ ។

គ្រប់ទង្វើរបស់ស្វ៍ឡាត់ត្រូវប្រព្រឹត្តទៅយ៉ាងរលូន ឥតចន្លោះខុសធម្មតា ។ ប្រសិនបើអ្នកណាឈប់ក្នុងស្វ៍ឡាត់ ដែលអ្នកមើលអាចស្មានបានថាអ្នកនោះមិនកំពុងតែបំពេញស្វ៍ឡាត់ទេ ស្វ៍ឡាត់របស់អ្នកនោះត្រូវមោឃៈ ។

**តារទីបនិងមូវ៉ាឡាត់ធ្វើឲ្យមុស្លីមទៅជាអ្នកមានសណ្តាប់ធ្នាប់និងមានវិន័យ**

**តាកុំគ្គីបាត់** (تعقبات)

តាក់គ្ហីបាត់មានន័យថាឌូអាុអ៍និងតាស់ប៊ីះហ៍ដែលគេសូត្រក្រោយស្វឡាត់ ។ គេឲ្យលើកតម្កើងអល់ឡោះហ្វ៍ﷻដោយសូត្រជាមួយផ្គាំផ្ទែអង្គាំបីឃ្លាដូចតទៅ គឺៈ

**អល់ឡ៉ហ្វូ បាក់បារ** **៣៤ ដង**
**អាល់ហ្វាំឌូលិលឡាស្វ** **៣៣ ដង**
**ស៊ុបហ្វាណល់ឡោះហ្វ៍** **៣៣ ដង**

គេហៅតាស់ប៊ីះហ៍នេះថា "តាស់ប៊ីហ៊ុស្ស ស្មាស្វរ៉អ៊ុ (تَسْبِيح الزَّهْرَاء)" ព្រោះរ៉ស្វូលុលឡោះហ្វ៍ﷺបានបង្ហាត់តាស់ប៊ីះហ៍នេះ ឲ្យបុត្រីជាទីស្រឡាញ់របស់ព្រះអង្គ ﷺ ដែលមានព្រះនាមថា ហ្វាទីម៉ាស្វ អាស្ស-ស្មាស្វរ៉អ៊ុعليها السلام ។

មានឌូអាុអ៍ច្រើនទៀតក្នុងតាក់គ្ហីបាត់ដែលអាចទន្ទេញចាំរត់មាត់បាន យ៉ាងហោចណាស់ឌូអាុអ៍ដែលគេសូត្រក្រោយស្វឡាត់ប្រចាំថ្ងៃ ។

នេះគឺឌូអាុអ៍ខ្លីមួយដកស្រង់ពីគួរអាន គឺៈ

| | |
|---|---|
| រ៉ប់បាណាក់ហ្វៀរ ឡាណា | -ព្រះម្ចាស់អើយ សូមព្រះអង្គអភ័យទោសឲ្យអស់ទូលព្រះបង្គំជាខ្ញុំ |
| វ៉ារហ្វាំណា | -សូមព្រះអង្គមានព្រះមេត្តាធម៌ ដល់អស់ទូលព្រះបង្គំជាខ្ញុំ |
| វ៉ា អាហ្វីណា | -សូមព្រះអង្គប្រទានសេចក្ដីសុខ ដល់អស់ទូលព្រះបង្គំជាខ្ញុំ |
| វ៉ាក់ហ្វូអាន់ណា | -សូមព្រះអង្គលុបលាងបាបអស់ទូលព្រះបង្គំជា ខ្ញុំ |
| ហ្វីដ្ឌុនយ៉ា វ៉ាល់ អាឃីរោះត៍ | -ក្នុងលោកនេះនិងលោកមុខ |
| អ៊ីនណាកា អាឡា គុល្លី | -ពិតណាស់ ព្រះអង្គមានមហិទ្ធិឫទ្ធិលើ |
| ស្ហៃអ៊ីនក៏ឌៀរ | -សព្វសារពើ |

**កុំប្រកាន់ខ្លួនពេកក្នុងការសូមអល់ឡោះហ្វ៍**

**មេរៀនទី ៦**

# ស្វ៉ឡាត់ - មូណាហ្វីយ៉ាត់ក្នុងស្វ៉ឡាត់(១)

**អ្វីដែលធ្វើឲ្យស្វ៉ឡាត់មោឃះ** (បាទិល)

មានច្រើនទង្វើដែលអាចធ្វើឲ្យស្វ៉ឡាត់របស់អ្នកមោឃះ ។ ប្រសិនបើវាកើតមានឡើងត្រូវបំពេញស្វ៉ឡាត់សាថ្មី ។

មាន ១២ មូណាហ្វីយ៉ាត់ក្នុងស្វ៉ឡាត់ គឺ៖

១. អ្វីៗដែលធ្វើឲ្យវូឌូអ៊ំមោឃះ ឧទាហរណ៍ ដេកលក់ ឬដើរខ្យល់ ។
២. បែរចេញពីគ៊ិបឡាស្ស ។
៣. គ្រប់ឥរិបថដែលបង្ហាញឲ្យឃើញថា ដូចជាមិនកំពុងបំពេញស្វ៉ឡាត់ទេ ឧទាហរណ៍ ទះដៃ ឬលោតជាដើម ។
៤. និយាយដោយចេតនា ។
៥. សើច ។
៦. យំដោយចេតនាដោយសារអ្វីមួយពាក់ព័ន្ធនឹងលោកសម្ភារនិយម ។
៧. ផឹក និង ស៊ី ។
៨. ឱបដៃដូចទង្វើរបស់មុស្លីមឯទៀតក្នុងស្វ៉ឡាត់ពួកគេ ។
៩. ថា "អាមីន" ក្រោយស៊ូរ៉ោះត៍ អាល់-ហ្វាំហ៍ ។
១០. អ្វីៗដែលមិនត្រឹមត្រូវក្នុងលក្ខខ័ណ្ឌចាំបាច់របស់ស្វ៉ឡាត់ ឧទាហរណ៍ ដឹងខ្លួនថា សំលៀកបំពាក់មិនបរិសុទ្ធ (ត៍ហ្វៀរ) ។
១១. មានការសង្ស័យក្នុងរ៉ក់អាត់ដំបូងទាំងពីររបស់ស្វ៉ឡាត់ស៊ូបុស្វ័, អាស្វ័រ, អ៊ីស្វាអ៍ និងក្នុងស្វ៉ឡាត់ស៊ូបហ្ស៍ និងម៉ាក់រីប ។
១២. ថែមឬចោលប៉ែករ៉ាយ៉ិប រុកន៍ (រូកុនរ៉ាយ៉ិប) របស់ស្វ៉ឡាត់ ។

**មូណាហ្វីយ៉ាត់មានន័យថាអ្វីដែលធ្វើឲ្យស្វ៉ឡាត់មោឃះ មាន ១២ ប្រការ**

# ស្វ៊ឡាត់ - មូណាហ្វីយ៉ាត់ក្នុងស្វ៊ឡាត់(២)

**អ្វីដែលធ្វើឲ្យស្វ៊ឡាត់មោឃៈ**

**១. អ្វីៗដែលធ្វើឲ្យវូឌុអ៊ុំមោឃៈ**

បើសិនជាក្នុងពេលស្វ៊ឡាត់មានអ្វីមួយដែលធ្វើឲ្យវូឌុអ៊ុំមោឃៈកើតឡើង (ដូចជាដើរខ្យល់ ដេកលក់ជាដើម...) ស្វ៊ឡាត់ទៅជាមោឃៈ ទោះបីទង្វើនោះកើតឡើងដោយចេតនា ឬដោយអចេតនាក៏ដោយ ។

**២. បែរចេញពីគ៊ីបឡាស់**

ក) យើងដឹងស្រាប់ហើយថា បែរចេញពីទិសគ៊ីបឡាស់ធ្វើឲ្យស្វ៊ឡាត់មោឃៈ បើបែរចេញលើសពី ៤៥˚ ទាំងសងខាង ។

ខ) ដូច្នេះ បើបែរចេញពីគ៊ីបឡាស់លើសពី ៤៥˚ ទោះដោយចេតនាក្តី ដោយអចេតនាក្តី ដោយសារមូលហេតុអ្វីផ្សេងក្តី ដូចជាខ្យល់ឬត្រូវច្រានជាដើម ។

គ) ក្នុងករណីបែរចេញលើសពី ៤៥˚ ទោះបីបែរតែក្បាល ឬបែរទាំងរាងកាយតែម្តងក៏ដោយ គឺដូចគ្នា ។

ឃ) ក្នុងករណីដែលការបែរចេញពីគ៊ីបឡាស់នោះធ្វើឲ្យស្វ៊ឡាត់មោឃៈ ត្រូវប្រតិបត្តិដូចតទៅ គឺៈ

-បើកើតឡើងដោយចេតនា ឬដោយសារអ្វីផ្សេង ស្វ៊ឡាត់ត្រូវមោឃៈ ។

-បើកើតឡើងដោយអចេតនា ហើយនឹកឃើញវិញក្រោយពេលស្វ៊ឡាត់បានហួសទៅហើយ (ឧទាហរណ៍ ស្វ៊ឡាត់អ៊ុស្ស៊ូរ ហើយនឹកឃើញវិញក្រោយម៉ាក់រីប) មិនបាច់ក៏ដ្វ៉ទេ ។

-បើកើតឡើងដោយអចេតនា ហើយនឹកឃើញវិញមុនហួសពេលស្វ៊ឡាត់ ត្រូវ

ធ្វើឡើងវិញ ។

### ៣. អ្វីដែលគេមិនអាចហៅថាស្វ៍ឡាត់បាន

ប្រសិនបើអ្នកណាមួយកំពុងតែបំពេញស្វ៍ឡាត់ ធ្វើអ្វីមួយដែលមុស្លីមត្រឹមត្រូវមើលមកឃើញថាផ្ទុយពីការបំពេញស្វ៍ឡាត់ ស្វ៍ឡាត់នេះត្រូវមោឃៈ ។ ឧទាហរណ៍ ទះដៃ លោតលេង ។ល ។ ទង្វើបែបនេះធ្វើឲ្យស្វ៍ឡាត់មោឃៈ ទោះបីដោយចេតនា ឬដោយអចេតនាក៏ដោយ ។
ក៏ប៉ុន្តែ កម្រើកដៃ ឬបង្ហាញអ្វីមួយឲ្យអ្នកណាម្នាក់ដោយដៃ មិនធ្វើឲ្យខូចស្វ៍ឡាត់ទេ ។

### ៤. និយាយដោយចេតនា

ប្រសិនបើនិយាយដោយចេតនាក្នុងពេលកំពុងតែស្វ៍ឡាត់ ស្វ៍ឡាត់នោះត្រូវខូច ទោះបីនិយាយជាមួយខ្លួនឯងឬជាមួយអ្នកដទៃក៏ដោយ ឬនិយាយដោយចាំបាច់ ។ បើមានការចាំបាច់ អ្នកអាចនិយាយបាន តែស្វ៍ឡាត់ត្រូវខូច អ្នកចាំបាច់ត្រូវបំពេញស្វ៍ឡាត់សាថ្មី ។

### ៥. សើចដោយចេតនា

សើចធ្វើឲ្យស្វ៍ឡាត់ខូច ។ ប្រសិនបើអ្នកចង់សើចខ្លាំង តែអ្នកទប់វាបានឡើងក្រហមមុខ ស្វ៍ឡាត់របស់អ្នកមិនខូចទេ វៀរលែងតែអ្នកសើច ។

សើចមិនរាប់បញ្ចូលជាញញឹមទេ ។ ញញឹមមិនធ្វើឲ្យស្វ៍ឡាត់ខូចទេ ។

**ស្វ៍ឡាត់ត្រូវប្រព្រឹត្តទៅដោយមានសតិអារម្មណ៍និងដោយមានចិត្ត**

**មេរៀនទី ៧**

# ស៊្វឡាត់ - ម៉ាសាអ៊ីល (مسائل បញ្ហា) នានា

## ១. របៀបបំពេញស៊្វឡាត់ពេលធ្វើដំណើរតាមយន្តហោះ តាមរថយន្ត ឬ តាមរថភ្លើង

ស៊្វឡាត់វ៉ាយីុបជាអ៊ីបាដាត់មហាសំខាន់មួយ ដែលមិនអាចបណ្តែតបណ្តោយបាន ទោះជានៅក្នុងស្ថានភាពណាក៏ដោយ ។ ធ្វើឲ្យស៊្វឡាត់វ៉ាយីុបទៅជាក៏ដ្ហ៍(قضى)ជាបាបធំមួយ ។ អ្នកជិតស្លាប់ក៏ដោយដែលនៅមានសតិអារម្មណ៍នៅឡើយត្រូវបំពេញស៊្វឡាត់ដែលអាចធ្វើទៅបាន ។

អ្នកធ្វើដំណើរតាមយន្តហោះ តាមរថយន្ត ឬតាមរថភ្លើង ត្រូវបំពេញស៊្វឡាត់ ប្រសិនបើអ្នកនោះគិតថាមុនបានដល់ទីដៅស៊្វឡាត់របស់ខ្លួននឹងទៅជាក៏ដ្ហ៍ ។

ត្រូវប្រតិបត្តិតាមតំណាក់ការដូចតទៅគឺះ

១. បើអាចធ្វើបាន ត្រូវយកទឹកវូឌុអ៊ុ ។ បើមិនបានទេ ត្រូវធ្វើតាយ៉ាំមុមជួស ។

២. បន្ទាប់មក រកគិ្ចបឡាស់ដោយត្រីវិស័យ ឬដោយសួរអ្នកដឹង ។

៣. រួចហើយ នៀតហើយតាក់ប៊ីរ៉ទុលអ៊ិះហ៊្រាំមដោយបែរទៅរកគិ្ចបឡាស់ ។ ក្រោយពីនោះមកមិនបាច់បែរទៅរកគិ្ចបឡាស់ទេបើយន្តហោះ រថយន្តឬរថភ្លើងប្តូរទិសដៅ ។

ល្អបំផុតបំពេញស៊្វឡាត់ឈរ បើអាចធ្វើបាន ពុំនោះទេស៊្វឡាត់អង្គុយ ។ បើស៊្វឡាត់បែបនេះក៏មិនអាចធ្វើបានដែរ គេអាចរូគុអ៊ុ សាជ៉ុដាស់ បំពេញទង្វើងទៀតដោយសញ្ញាត្របកភ្នែក ។

ច្បាប់សំខាន់ គឺឲ្យខ្លួនប្រាណនិងសំលៀកបំពាក់ស្អាត ។ ប្រសិនបើវាទៅជាណាយ៉ីសក្នុងពេលធ្វើដំណើរ ហើយអាចផ្លាស់បាន ត្រូវផ្លាស់វាចេញ ។

បើមិនអាចធ្វើបានទេ ត្រូវតែបំពេញស្វ៍ឡាត់ តែត្រូវក៏ដ៏ក្រោយមក ។

**២. អាល់ហ៊ាដ្យាស្ស៍ (ឧបត្ថិហេតុ)**

បើមានបញ្ហាពាក់ព័ន្ធនឹងការបត់ជើងតូច ការដើរខ្យល់ ឬផ្សេងទៀត តើច្បាប់ស្ហារីអ៊ុស្សំចែងអ្វីខ្លះ ?

បើអ្នកណាមានជម្ងឺទប់បត់ជើងតូចមិនបាន ឬទប់បត់ជើងធំមិនបាន ឬទប់ដើរខ្យល់មិនបាន អ្នកនោះត្រូវប្រតិបត្តិដូចតទៅគឺ៖

១. បើអ្នកនោះជឿជាក់ថាអាចស្វ៍ឡាត់បាន ក្រោយវ៉ូឌុអ៍ ក្នុងអំឡុងពេលរបស់ស្វ៍ឡាត់នោះ គប្បីស្វ៍ឡាត់ក្នុងអំឡុងពេលនោះ (ដែលនៅក្នុងចន្លោះពេលអាវ៉ាល់និងពេលក៏ដ៏)

២. បើអ្នកនោះអាចទប់បត់ជើងតូច ឬបត់ជើងធំ ឬដើរខ្យល់ បានតែក្នុងអំឡុងពេលធ្វើទង្វើវ៉ាយ៉ីបប៉ុណ្ណោះ អ្នកនោះត្រូវចោលទង្វើស៊ូណាត់ (អ៊ីក៏ម៉ាត់អាស្ហាន គូនូត ។ល ។)

បើជាឡើងវិញពីជម្ងឺទប់បត់ជើងតូច ឬបត់ជើងធំ ឬដើរខ្យល់មិនបាននោះ មិនចាំបាច់ក៏ដ៏ស្វ៍ឡាត់ដែលបានធ្វើហើយទេកាលដែលនៅមានជម្ងឺនោះ ។ តែបើជាពីជម្ងឺវិញនៅក្នុងពេលដែលកំពុងបំពេញស្វ៍ឡាត់ណាមួយ ត្រូវក៏ដ៏ស្វ៍ឡាត់នោះឡើងវិញ ។

**៣. ស្វ៍ឡាត់ក៏ដ៏ - ធ្វើសងដូចម្តេច**

អ្នកណាមិនបានបំពេញស្វ៍ឡាត់វ៉ាយ៉ីបទាន់ពេលវេលាកំណត់ ត្រូវបំពេញស្វ៍ឡាត់

កុំជំ (គឺសង) វិញ ទោះបីអ្នកនោះបានដេកលក់ពេញមួយពេលរបស់ស្វឡាត់នោះក៏ដោយ ឬទោះបីអ្នកនោះបានបាត់បង់សតិអារម្មណ៍ក្នុងអំឡុងពេលនោះក៏ដោយ ។

មិនចាំបាច់ធ្វើតាមលេខរៀងរបស់ស្វឡាត់កុំជំទេ លើកលែងតែករណីស្វឡាត់ដែលច្បាប់ចែងមកដោយមានលេខរៀង ។

ឧទាហរណ៍ ប្រសិនបើអ្នកមិនបានបំពេញស្វឡាត់ស៊ុហ្វរ៍និងស្វឡាត់អាស្វរ៍ទេ ពេលបំពេញស្វឡាត់កុំជំ អ្នកត្រូវបំពេញស្វឡាត់ស៊ុហ្វរ៍មុនស្វឡាត់អាស្វរ៍ ។ ប្រសើរបំផុតឲ្យរក្សាលេខរៀងនេះ ។ ដូចគ្នាដែរ ប្រសិនបើអ្នកមិនបានបំពេញស្វឡាត់ស៊ុបហ៍ទេ ប្រសើរបំផុតឲ្យកុំជំស្វឡាត់ស៊ុបហ៍សិនមុនបំពេញស្វឡាត់ស៊ុហ្វរ៍ ។

ប្រសិនបើអ្នកណាមិនបានបំពេញស្វឡាត់ណាមួយ មិនបង្ខំខ្លួនឯងឲ្យកុំជំទេ ថ្វីបើមានលទ្ធភាពគ្រប់គ្រាន់នោះ អ្នកនោះប្រព្រឹត្តខុសនិងប្រព្រឹត្តល្មើសយ៉ាងជាក់ស្តែងចំពោះបទបញ្ជាអល់ឡោះហ្ ﷻ ។
ក្រោយពីអ្នកនោះស្លាប់ទៅ កូនប្រុសបងគេរបស់អ្នកនោះចាំបាច់ត្រូវកុំជំស្វឡាត់របស់អ្នកនោះ ឬត្រូវជួលគេកុំជំស្វឡាត់នោះ ។ រីឯស្វឡាត់កុំជំរបស់ម្តាយ មិនចាំបាច់ឲ្យកូនប្រុសបងគេធ្វើទេ តែប្រសើរបំផុតគប្បីធ្វើ ។

ប្រសិនបើកូនប្រុសបងគេសង្ស័យថាឪពុកខ្លួនមាន ឬមិនមានស្វឡាត់ដែលត្រូវកុំជំទេនោះ គេមិនចាំបាច់កុំជំទេ ។

**មេរៀនទី ៨**

# ស្វ៉ឡាត់ - ម៉ាសាអ៊ីល (បញ្ហា) នានា(២)

**៤. ទណ្ឌកម្មនិងការខូចប្រយោជន៍ដោយសារពន្យារពេលស្វ៉ឡាត់រ៉ាយ៉ិប ដោយសារធ្វើឲ្យទៅជាក៏ដ្វ៉ (ផុតពេល) ឬមិនអើពើតែម្តង**

ស្វ៉ឡាត់ជាវិធីគោរពបូជាដែលត្រូវបញ្ញត្តក្នុងសាសនាអ៊ីស្លាម ។ គោរពបូជាគឺការចុះចូលចំពោះអល់ឡោះហ្វ៍ﷻ ។

អល់ឡោះហ្វ៍ﷻធំជាងគេបំផុត ! មិនមានអ្វីប្រៀបផ្ទឹមឡើយ ។ ពេលណាអល់ឡោះហ្វ៍ហៅអ្នក (នៅពេលស្វ៉ឡាត់) ពេលនោះត្រូវទុកភារកិច្ចលោកីយ៍មួយអន្លើសិន ។ **ចូរកុំខកខានក្នុងឱកាសមាសនេះឡើយ** ។ ចូរទៅស្វ៉ឡាត់ក្នុងវត្តមានអល់ឡោះហ្វ៍ﷻ ។ ព្រះអង្គទ្រង់ធំសម្បើមណាស់ បញ្ហាយើង ការព្រួយបារម្ភឬឧបសគ្គយើងនឹងមានដំណោះស្រាយបើយើងសូមព្រះអង្គដោយស្មោះ ។ មិនត្រឹមតែប៉ុណ្ណោះទេ សេចក្តីសប្បាយ ជោគជ័យនិងគោលដៅយើងច្បាស់ជាបានសម្រេច ។ យើងអាចចរចាប្រស្រ័យជាមួយព្រះអង្គដូចម្តេចទៅ ។ មានតែសេចក្តីស្រឡាញ់និងសេចក្តីប្រោសប្រណីរបស់ព្រះអង្គទេដែលអាចផ្តល់ឲ្យនូវសេចក្តីចម្រើនក្នុងលោកនេះ និងក្នុងលោកមុខ ។

បើអ្នកបំពេញស្វ៉ឡាត់ទាន់ពេលកំណត់ ហើយបន្តកិច្ចការផ្សេងៗនៅពេលក្រោយ អ្នកនឹងមានអារម្មណ៍ថាស្កប់ចិត្ត ។ **សាកល្បងមើលទៅ**!

អ្នកប្រើពេល ៣០ នាទីសម្រាប់បំពេញ ១៧ រ៉ក់អាត់ ដោយបូកបញ្ចូលតាក់គ៌ីបាត់ (تعقيبات) ផង សរុបមាន ៤៥ នាទីក្នុងមួយថ្ងៃ ។ អ្នកគិតថាច្រើនឬ អល់ឡោះហ្វ៍ﷻ ព្រះរាជទានឲ្យយើង ២៤ ម៉ោងក្នុងមួយថ្ងៃ ?

សម័យថ្ងៃមួយ ពេលដែលរ៉សូលុលឡោះហ្វ៍ﷺនៅក្នុងម៉ាស់យ៉ិដណាបាវី បុរសម្នាក់

បានចូលមក ហើយបានបំពេញស្ឡឺឡាត់យ៉ាងលឿន មិនបានបំពេញរូគុអ៊ំនិងសាចុំដ្ងាស់ដោយផ្ចិតផ្ចង់ទេ ។ ព្រះសាស្ដាﷺមានព្រះវចនៈថាៈ "បើបុរសនេះនៅតែបំពេញស្ឡឺឡាត់បែបនេះហើយស្លាប់ គាត់នឹងមិនស្លាប់ក្នុងសាសនាខ្ញុំទេ (ក្នុងឋានៈជាមុស្លីម) ។ ដូច្នេះ មិនត្រូវបំពេញស្ឡឺឡាត់លឿនទេ ។ ក្នុងពេលបំពេញស្ឡឺឡាត់ត្រូវនឹកដល់អល់ឡោះហ៍ﷻជានិច្ច ហើយបំពេញនមស្ការយ៉ាងរាបសា ។ ដល់ពេលបំពេញស្ឡឺឡាត់ គេត្រូវស្មារលាកំហុស ។

អ្នកណាចាត់ទុកថាស្ឡឺឡាត់ជាអ្វីមួយធម្មតា មិនមានសារសំខាន់ អ្នកនោះនៅក្នុងចំពូកមនុស្សដែលមិនបានបំពេញស្ឡឺឡាត់ទាល់តែសោះ ។

ព្រះសាស្ដាﷺមានព្រះវចនៈថា អ្នកណាមិនចាត់ទុកថាស្ឡឺឡាត់សំខាន់ទេ ហើយគិតថាឥតប្រយោជន៍ អ្នកនោះសមនឹងទទួលរងនូវទារុណកម្មនៅលោកមុខ (ពោលគឺ ក្នុងផ្នូរនិងក្នុងឋាននរក) ។

អល់ឡោះហ៍ﷻមានព្រះរាជបន្ទូលក្នុងព្រះមហាគម្ពីរគួរអានថាអ្នកណាគេចវេះបំពេញស្ឡឺឡាត់ អ្នកនោះអាចនឹងទៅជាកាហ្វៀរ ។ អ្នកណាមិនព្រមបំពេញស្ឡឺឡាត់ទេ អ្នកនោះបដិសេធមិនទទួលស្គាល់ថាមានអល់ឡោះហ៍ﷻ ហើយជាមុស្លីមតែឈ្មោះទេ ។

**អ្នកនោះសមនឹងរងទណ្ឌកម្មអល់ឡោះហ៍យ៉ាងធ្ងន់**

## ៥. សារសំខាន់របស់ការបំពេញស្ឡឺឡាត់ទៀងពេល

១. បំពេញស្ឡឺឡាត់យ៉ាងទៀងទាត់ក្នុងពេលកំណត់ ធ្វើឲ្យស្មារតីទៀងទាត់កាន់តែរីកចម្រើនឡើង ។
២. ស្ឡឺឡាត់ធ្វើឲ្យមនុស្សស្អាតស្អំនិងមានសណ្ដាប់ធ្នាប់ រាងកាយរបស់គេមានការយកចិត្តទុកដាក់និងមានរបៀបរបប ចិត្តគេបរិសុទ្ធ ។
៣. អ្នកបំពេញស្ឡឺឡាត់លាងដៃ លាងមាត់ ។ល ។ ប្រាំដងមួយថ្ងៃ ។ ប្រតិបត្តិបែប

នេះកម្ចាត់អាការធុញទ្រាន់ ។

៤. អល់ឡោះហ៍عزّوجلّទ្រង់ព្រះរាជទានចំណេះ ជំនឿ និងសុខភាពឲ្យអ្នកបំពេញស្វ៍ឡាត់ ។

៥. អល់ឡោះហ៍عزّوجلّទ្រង់សព្វព្រះឫទ័យអ្នកបំពេញស្វ៍ឡាត់ ព្រមទាំងព្រះសាស្តាصلى الله عليه وآله وسلم និងព្រះសន្តអ៊ីមុាំعليهم السلام ។

៦. ស្វ៍ឡាត់ធ្វើឲ្យចិត្តថ្កើងថ្កាន ជម្រះមន្ទិល រម្ងាប់ចិត្ត កម្ចាត់ឧបសគ្គខាងមុខ និងដោះស្រាយបញ្ហា ។

៧. រ៉ស៊ូលុលឡោះហ៍صلى الله عليه وآله وسلمមានព្រះវចនៈថា ស្វ៍ឡាត់ជាមេត្តាធម៌សម្រាប់អ្នកមានសទ្ធា ។

៨. ស្វ៍ឡាត់នឹងជួយយើងក្នុងលោកមុខ ។ ទេវតានឹងបួងសួងសូមខមាទោសឲ្យយើង និងជួយយើង ។ ស្វ៍ឡាត់ក្នុងលោកនេះជាចង្កៀងឬជាពន្លឺយើងនៅក្នុងផ្នូរ ។

**គេនឹងព្រមទទួលទង្វើល្អទាំងអស់របស់បុគ្គល ប្រសិនបើអល់ឡោះហ៍عزّوجلّព្រមទទួលស្វ៍ឡាត់របស់បុគ្គលនោះ ។ ប្រសិនបើស្វ៍ឡាត់យើងត្រូវច្រានចោល គេនឹងមិនព្រមទទួលទង្វើល្អណាមួយរបស់យើងទេ ។**

យើងបានយល់សេចក្តីពណ៌នារបស់ស្វ៍ឡាត់ហើយ សង្ឃឹមថាម្នាក់ៗនឹងបំពេញស្វ៍ឡាត់ក្នុងពេលកំណត់យ៉ាងត្រឹមត្រូវ ។ តែចូរពិចារណាបន្តិចថា៖

អ្នកបំពេញស្វ៍ឡាត់ព្រោះតែ៖

ក) អ្នកខ្លាចអល់ឡោះហ៍ ? បើដូច្នេះមែន អ្នកបំពេញស្វ៍ឡាត់របស់ទាសៈ ។

ខ) អ្នកស្វែងរករង្វាន់ ? បើដូច្នេះមែន អ្នកបំពេញស្វ៍ឡាត់របស់ឈ្មួញ ។

គ) ព្រះអង្គសមជាទីគោរពបូជា និងសមជាទីបំរើ ? បើដូច្នេះមែន នេះគឺស្វ៍ឡាត់ប្រសើរបំផុត ។

ចូរចងចាំថា អ៊ីមុាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "ប្រសិនបើអ្នកបំពេញស្វ៍ឡាត់ដឹងថាប៉ុន្មានព្រះមេត្តាធម៌របស់អល់ឡោះហ៍ត្រូវប្រទានមកលើខ្លួនគេ ក្នុងពេលគេបំពេញ

ស្ទ័ឡាត្ទ័នោះ អ្នកនោះច្បាស់ជាមិនព្រមងើបក្បាលឡើងពីការក្រាបណិប័តន៍ទេ !"

## ស្ទ័ឡាត្ទ័កម្ចាត់ភាពងងឹតពីក្នុងចិត្តដោយពន្លឺអភិវាទន៍

## មេរៀនទី ៩

# ស្ហ៏ឡាត់ - កន្លែងស្ហ៏ឡាត់

### ម៉ាសាអ៊ីលចាំបាច់

១. មិនអនុញ្ញាតឲ្យបំពេញស្ហ៏ឡាត់លើកន្លែងកុស្ហ៊ុបឺ (غصب របស់អ្នកដទៃ) ដោយឥតបានទទួលការអនុញ្ញាតទេ ។

២. កន្លែងសាច់ដាស់ត្រូវបរិសុទ្ធ (ត៏ហ្ហៀរ) ។ កន្លែងសម្រាប់ឈរនិងអង្គុយអាចមិនត៏ហ្ហៀរ កុំឲ្យតែណាយ៉ីស (نجس) រាលដាលមកដល់រាងកាយនិងសំលៀកបំពាក់របស់អ្នកស្ហ៏ឡាត់ ។

៣. មិនអនុញ្ញាតឲ្យបំពេញស្ហ៏ឡាត់លើកន្លែងណា ដែលអ្នកស្ហ៏ឡាត់មិនអាចបិតនៅនឹងមួយកន្លែងយ៉ាងល្អបាន ឬដែលមានគ្រោះថ្នាក់ ឧទាហរណ៍ លើផ្លូវដែលមានការទៅមកច្រើន ។

៤. កន្លែងអ្នកស្ហ៏ឡាត់មិនត្រូវអស្ថិរវរ (មិនជាប់ ឬមិននឹង) ទេ ដូចជាពូកជាដើម ។

៥. កន្លែងត្រូវមានទំហំគ្រប់គ្រាន់សម្រាប់រូគុអ៊ុំនិងសម្រាប់សាច់ដាស់បាន យ៉ាងត្រឹមត្រូវ ។

៦. នារីគប្បីនៅខាងក្រោយបុរសពេលបំពេញស្ហ៏ឡាត់ ។ យ៉ាងហោចណាស់ឲ្យកន្លែងសាច់ដ្ហាស់នៅស្មើនឹងជួរដែលបុរសដាក់ភ្លៅ ។ ឬឲ្យមានវាំងននឬជញ្ជាំងនៅត្រង់ចន្លោះពួកគេ ។

៧. កុំឲ្យកន្លែងដាក់ថ្ងាសនៅពេលសាច់ដ្ហាស់ខ្ពស់ឬទាប ៤ ធ្លាប់ (បួនម្រាមដៃ) ជាងកន្លែងដាក់ជង្គង់និងម្រាមជើង ។

### ម៉ាស់យ៉ីដ្ហ

គេបញ្ជាក់ថាឲ្យបំពេញស្ហ៏ឡាត់ក្នុងម៉ាស់យ៉ីដ្ហ ។ ម៉ាស់យ៉ីដ្ហប្រសើររៀងតាមលំដាប់គឺមាន៖

១. ម៉ាស់យ៉ិឌុល ហ្ការ៉ម (នៅជុំវិញកាក់បាស្ហ) ។ ស្វ៍ឡាត់នៅទីនេះស្មើ ១០០ ០០០ ស្វ៍ឡាត់នៅទីផ្សេងទៀត ។
២. ម៉ាស់យ៉ិឌុន ណាប៊ី (ម៉ាឌីណាស្ហ) ។ ស្វ៍ឡាត់នៅទីនេះស្មើ ១០ ០០០ ស្វ៍ឡាត់នៅទីផ្សេងទៀត ។
៣. ម៉ាស់យ៉ិឌុល គូហ្វាស្ហ និង បៃទុល មុកក៌ដ្ឋាស់ ។ ស្វ៍ឡាត់នៅទីនេះស្មើ ១០០០ ស្វ៍ឡាត់នៅទីផ្សេងទៀត ។
៤. ម៉ាស់យ៉ិដ្ឋ យ៉ាមីយ៉ា (ម៉ាស់យ៉ិដ្ឋស្រុក) ។ ស្វ៍ឡាត់នៅទីនេះស្មើ ១០០ ស្វ៍ឡាត់នៅទីផ្សេងទៀត ។
៥. ម៉ាស់យ៉ិដ្ឋសង្កាត់ (ម៉ាស់យ៉ិដ្ឋជិតខាង) ។ ស្វ៍ឡាត់នៅទីនេះស្មើ ១២ ស្វ៍ឡាត់នៅទីផ្សេងទៀត ។

សម្រាប់នារី ផ្ទះខ្លួនឯងប្រសើរជាងម៉ាស់យ៉ិដ្ឋ ។

ព្រះសាស្តាﷺយើងមានព្រះវចនៈថាម៉ាស់យ៉ិដ្ឋនឹងត្អូញប្រាប់អល់ឡោះហ្វ៍ﷻ បើគេលែងអើពើវា ឬពុំមានមនុស្សមកស្វ៍ឡាត់ទេ ។

ម៉ាស់យ៉ិដ្ឋល្បីជាងគេគឺម៉ាស់យ៉ិឌុល ហ្ការ៉ម នៅជុំវិញកាក់បាស្ហ ។ រង្វាន់មួយរ៉ក់អាត់ស្មើ ១០០០០០ រ៉ក់អាត់ស្វ៍ឡាត់នៅឯទីផ្សេង ។

**កន្លែងដែលម៉ាក់រុះហ្វ៍(مكروه)បំពេញស្វ៍ឡាត់ (យកល្អឲ្យចៀសវាង)**

១. កន្លែងងូតទឹកសាធារណៈ ។
២. ដីប្រៃ ។
៣. ទល់មុខមនុស្ស ។
៤. ទល់មុខទ្វារបើក ។
៥. លើផ្លូវ លើកលែងតែបំពេញស្វ៍ឡាត់នៅទីនោះមិនធ្វើឲ្យអ្នកផងរំខាន ។ បើដូច្នេះ ហ្វារាំមិនឲ្យបំពេញស្វ៍ឡាត់នៅទីនោះទេ ។
៦. ទល់មុខភ្លើងឬចង្កៀង ។
៧. ក្នុងផ្ទះបាយ ឬកន្លែងណាដែលមានឡ ។

៨. ទល់មុខអណ្តូង ឬណ្តៅដែលគេបត់ជើងតូចដាក់ជាញឹកញយ ។

៩. កន្លែងដែលមានរូប (គំនូរ រូបថត ។ល ។) ទោះបីមិននៅទល់មុខអ្នកស្ម័គ្រទ្បាត់ក៏ដោយ ។

១០. ទល់មុខផ្នូរ លើផ្នូរ ក្នុងចន្លោះផ្នូរ ឬនៅក្នុងស្មសាន (ទីបញ្ចុះសព) ។

**មេរៀនទី ១០**

# ស្ញ៉ឡាត់ - សំលៀកបំពាក់សម្រាប់ស្ញ៉ឡាត់

ត្រូវគោរពវិន័យមួយចំនួនពាក់ព័ន្ធនឹងសំលៀកបំពាក់ពេលបំពេញស្ញ៉ឡាត់ គឺៈ

១. សំលៀកបំពាក់ត្រូវតុំហ្ញៀរ (បរិសុទ្ធ) ។ ស្ញ៉ឡាត់ជាមួយសំលៀកបំពាក់ណាញ៉ីសត្រូវមោឃៈ ។
២. សំលៀកបំពាក់ត្រូវមូបាស្ញ (مباح) មិនកុស្ញ៉បី ។ ស្ញ៉ឡាត់ជាមួយសំលៀកបំពាក់កុស្ញ៉បីត្រូវមោឃៈ ។ សំលៀកបំពាក់ដែលគេទិញដោយប្រាក់ដែលមិនបានបង់ស្សាកាត់ឬឃុមស៍ (កាលណាស្សាកាត់ឬឃុមស៍នោះវ៉ាញ៉ីប) ជាសំលៀកបំពាក់កុស់បី ហើយស្ញ៉ឡាត់ជាមួយសំលៀកបែបនេះត្រូវមោឃៈ ។
៣. មិនត្រូវជាប៉ែកណាមួយរបស់សត្វដែលហ្ញារាំបរិភោគសាច់ទេ ។ ដូច្នេះ រោមឆ្មា ឬរោមសត្វចំពូកនេះមិនត្រូវអនុញ្ញាតក្នុងស្ញ៉ឡាត់ទេ ។
៤. មិនត្រូវជាប៉ែកណាមួយរបស់សត្វស្លាប់ទេ ។ ខ្សែក្រវ៉ាត់ឬរបស់ធ្វើអំពីស្បែកសត្វមិនត្រូវអនុញ្ញាតទេ វៀរលែងតែវាស្របតាមច្បាប់ស្សាបីហ្ញាស់ (ذبيحة ពោលគឺ មកពីសត្វហ្ញាឡាល់សំឡែះតាមច្បាប់អ៊ីស្លាម) ឬទិញមកពីមុស្លីម (ដោយដឹងថាគេស្គាល់បុគ្គលនេះ ឬយ៉ាងហោចណាស់គួរឲ្យជឿថាមុស្លីមនេះបានទិញមកក្រោយពីបានពិនិត្យមើលច្បាស់ហើយ) ។
៥. សម្រាប់តែមនុស្សប្រុសទេ មិនត្រូវពាក់មាស (មាសសុទ្ធឬមាសលាយ) ។ មិនខុសទេបើមានអ្វីមួយធ្វើអំពីមាសនៅក្នុងហោប៉ៅ ។
៦. សម្រាប់តែមនុស្សស្រី មិនត្រូវស្លៀកពាក់អ្វីដែលធ្វើអំពីសូត្រសុទ្ធទេ ។

មាសនិងសូត្រសុទ្ធត្រូវហាមគ្រប់ពេលចំពោះមនុស្សប្រុស ជាពិសេសក្នុងពេលស្ញ៉ឡាត់ ។ ពោលគឺសព្វវត្ថុដែលធ្វើអំពីមាស កងដៃ វ៉ែនតា ចិញ្ចៀន ខ្សែក... ។ តែសម្រាប់មនុស្សស្រី មាសនិងសូត្រសុទ្ធត្រូវអនុញ្ញាតគ្រប់ពេល លើកលែងតែសូត្រសុទ្ធក្នុងពេលស្ញ៉ឡាត់ទេ ។

**វិន័យ (ហ្វូកុម) ផ្សេងៗទៀត**

១. ប្រសិនបើបុគ្គលណាមិនដឹងថារាងកាយ ឬសំលៀកបំពាក់របស់ខ្លួនឯងណាយ៉ីសទេ ហើយបានដឹងក្រោយពីបានស្ម័ឡាត់រួច ស្ម័ឡាត់របស់អ្នកនោះមិនមោឃៈទេ ។

២. បើបុគ្គលនោះដឹងថារាងកាយ ឬសំលៀកបំពាក់របស់ខ្លួនឯងណាយ៉ីសហើយភ្លេច បានបំពេញស្ម័ឡាត់ក្នុងសភាពនេះ រួចហើយនឹកឃើញវិញក្រោយស្ម័ឡាត់ អ្នកនោះគប្បីបំពេញស្ម័ឡាត់សាឡើងវិញ (បន្ទាប់ពីបានសម្អាតហើយ) បើនៅសល់ពេល ឬ បំពេញស្ម័ឡាត់ក៏ដ៏បើផុតពេលហើយ ។

៣. ប្រសិនបើសំលៀកបំពាក់ទៅជាណាយ៉ីសក្នុងស្ម័ឡាត់ ហើយបើអាចយកណាយ៉ីសនោះចេញបាន ឬអាចធ្វើឲ្យបរិសុទ្ធបានដោយមិនរំខានស្ម័ឡាត់ទេ បុគ្គលនោះត្រូវធ្វើដូច្នេះ ស្ម័ឡាត់នឹងមិនខូចទេ ។ ប្រសិនបើយកចេញមិនបាន ឬមិនអាចធ្វើឲ្យបរិទ្ធស្អាតវិញបានទេ ហើយបើនៅសល់ពេល បុគ្គលនោះត្រូវឈប់ស្ម័ឡាត់ ជម្រះឲ្យបរិសុទ្ធ ហើយបំពេញស្ម័ឡាត់សាឡើងវិញ ។ ប្រសិនបើមិនមានពេលគ្រប់គ្រាន់ទេ ហើយមិនអាចដោះសំលៀកបំពាក់នោះបានទេ បុគ្គលនោះត្រូវស្ម័ឡាត់ឲ្យចប់ជាមួយសំលៀកបំពាក់នោះ ស្ម័ឡាត់មិនខូចទេ ។ ប្រសិនបើបុគ្គលនេះអាចដោះសំលៀកបំពាក់ណាយ៉ីសនោះបាន តែមិនមានសំលៀកបំពាក់ផ្សេងទេ បុគ្គលនោះត្រូវបំពេញស្ម័ឡាត់លុះចប់ជាមួយសំលៀកបំពាក់នោះ ។ ប្រើវិន័យនេះដែរពេលណាប៉ែករាងកាយណាមួយទៅជាណាយ៉ីសក្នុងពេលស្ម័ឡាត់ ។

៤. គេអត់ឱនឲ្យក្នុងពេលស្ម័ឡាត់ចំពោះណាយ៉ីសទាំងនេះគឺៈ

ក) ឈាមដែលចេញមកពីមុខរបួសឬដំបៅ បើពិបាកយកចេញឬផ្លាស់ក្រណាត់រុំយ៉ាងហោចណាស់មួយថ្ងៃម្តង ។ តែបើឈាមនោះហូរទៅលើប៉ែកមួយទៀតរបស់រាងកាយ (ឆ្ងាយពីរបួស) ត្រូវជម្រះប៉ែកនោះឲ្យបរិសុទ្ធវិញ ។

ខ) ឈាម (ផ្សេងពីឈាមសព ឬឈាមកាហ្វៀរ ឬឈាមសត្វដែលសាច់មិន

ហ្វាឡាល់) នៅលើសំលៀកបំពាក់ ឬលើខ្លួនរបស់អ្នកស្ឋ៍ឡាត្ទ់ ដែលមិនធំជាងចុងម្រាមដៃចង្អុល ។

គ) វត្ថុដែលគេមិនប្រើសម្រាប់បិទបាំងខ្មាស់មនុស្សទេ ព្រោះតែតូចពេក ។ ឧទាហរណ៍ កន្សែងដៃ លេវ ចិញ្ចៀន ។ល ។ កុំឲ្យតែវាធ្វើអំពីសារធាតុណាយ៉្ជីស ។

ប្រសិនបើពុំមានសំលៀកបំពាក់ផ្សេងពីកុស្ហ៍ប៊ី (លួចគេ) ឬធ្វើអំពីមាស ឬសូត្រ ហើយបុគ្គល នោះចាំបាច់ត្រូវតែពាក់វា ដោយសារតែរងា ឬដោយសារតែមនុស្សឯទៀតនៅជុំវិញខ្លួន បុគ្គលនោះអាចបំពេញស្ឋ៍ឡាត្ទ់ជាមួយវាបាន តែបើអាចធ្វើទៅបាន បុគ្គលនោះត្រូវដោះវាចេញ ហើយបំពេញស្ឋ៍ឡាត្ទ់ឥតសំលៀកបំពាក់ក្នុងបន្ទប់បិទទ្វារជិត ។

ប្រើវិន័យនេះដែរ បើបុគ្គលនោះមិនមានសំលៀកបំពាក់ផ្សេងពីសំលៀកបំពាក់កុស្ហ៍ប៊ីទេ ឬសំលៀកបំពាក់ធ្វើអំពីស្បែកសត្វស្លាប់ឬសត្វហ្វារ៉ាំ (ហាមបរិភោគ) ។

ប្រសិនបើមិនមានសំលៀកបំពាក់ផ្សេងពីសំលៀកបំពាក់មិនបរិសុទ្ធ (ណាយ៉្ជីស) ទេ ហើយមិនអាចជម្រះបន្សុទ្ធវាបានទេ បុគ្គលនោះត្រូវបំពេញស្ឋ៍ឡាត្ទ់ជាមួយសំលៀកបំពាក់នោះ ស្ឋ៍ឡាត្ទ់នឹងត្រឹមត្រូវ មិនខូចទេ ។

**មេរៀនទី ១១**

# ស្វ៏ឡាត់ - ពេលវេលាស្វ៏ឡាត់

**ពេលវេលាសម្រាប់បំពេញស្វ៏ឡាត់ប្រចាំថ្ងៃមានដូចតទៅគឺ៖**

ក. **ស៊ូបហ៍** (ស្វ៏ឡាត់ហ្វាច់រ៍) - ចាប់ផ្ដើមនៅពេលស៊ូបហ៍ស្វ៏ឌិក ចប់នៅពេលថ្ងៃរះ ។

ខ. **ស៊ូហ្វុរ៍** (ស្វ៏ឡាត់ពាក់កណ្ដាលថ្ងៃ) - ចាប់ផ្ដើមនៅពេលថ្ងៃជ្រេ ចប់នៅពេលដែលល្មមតែបំពេញស្វ៏ឡាត់ ៤ រ៉ក់អាត់បានមុនថ្ងៃលិច ។

គ. **អាស្វ៏រ៍** (ស្វ៏ឡាត់ពេលថ្ងៃរសៀល) - ចាប់ផ្ដើមនៅក្រោយពេលដែលអាចបំពេញស្វ៏ឡាត់ ៤ រ៉ក់អាត់បាន (គឺក្រោយស្វ៏ឡាត់ស៊ូហ្វុរ៍) ចប់នៅពេលថ្ងៃលិច ។

ឃ. **ម៉ាក់រីប** (ស្វ៏ឡាត់ពេលព្រលប់) - ចាប់ផ្ដើមនៅពេលក្រោយថ្ងៃលិច ចប់នៅពេលសល់ពេលល្មមតែបំពេញស្វ៏ឡាត់ ៤ រ៉ក់អាត់បាននៅពាក់កណ្ដាលអធ្រាត្រ ។

ង. **អ៊ីស្វាអ៍** (ស្វ៏ឡាត់ពេលយប់) - ចាប់ផ្ដើមនៅក្រោយពេលដែលល្មមបំពេញស្វ៏ឡាត់ ៣ រ៉ក់អាត់បាន (គឺស្វ៏ឡាត់ម៉ាក់រីប) ចប់នៅពេលពាក់កណ្ដាលអធ្រាត្រ ។

**អធិប្បាយលំអិត**

១. ពេល**ហ្វាឌីឡាត់** យកល្អត្រូវបំពេញស្វ៏ឡាត់នៅពេលហ្វាឌីឡាត់ ព្រោះបានរង្វាន់ច្រើន ។ ពេលហ្វាឌីឡាត់សម្រាប់ស្វ៏ឡាត់ប្រចាំថ្ងៃមានដូចតទៅ គឺ៖

ក) **ស៊ូបហ៍** ចាប់ផ្ដើមនៅពេលស៊ូបហ៍ស្វ៏ឌិករហូតដល់មានពណ៌ក្រហមនៅជើង

មេឃ ។

ខ) **ស៊្មុំស្វរ៍** ចាប់ផ្តើមពីពាក់កណ្តាល (គឺពេលថ្ងៃត្រង់) ថ្ងៃរហូតដល់ពេលដែលស្រមោលរបស់វត្ថុអ្វីមួយមានប្រវែងស្មើវត្ថុនោះ ។

គ) **អាស្ស៊រ៍** ក្រោយពេលហ្វាឌ្វីឡាត់របស់ស្វ៉ឡាត់ស៊្មុំស្វរ៍ រហូតដល់ពេលដែលស្រមោលរបស់វត្ថុអ្វីមួយមានប្រវែងលើសវត្ថុនោះពីរដង ។

ឃ) **ម៉ាក់រីប** ក្រោយថ្ងៃលិចរហូតដល់ពណ៌ក្រហមបាត់ពីជើងមេឃ ។

ង) **អ៊ីស្ហាអ៍** ក្រោយពេលហ្វាឌ្វីឡាត់របស់ម៉ាក់រីប ។

## ២. ពេលដាច់ខ្សែក និង ពេលរួម

ក) **ស៊្មុំស្វរ៍** - អំឡុងពេលស្វ៉ឡាត់ ៤ រ៉ក់អាត់ក្រោយពាក់កណ្តាលថ្ងៃជាពេលដាច់ខ្សែកសម្រាប់តែស្វ៉ឡាត់ស៊្មុំស្វរ៍ទេ ។ បើអ្នកណាបំពេញស្វ៉ឡាត់អាស្ស៊រ៍ក្នុងពេលនេះ ស្វ៉ឡាត់នោះត្រូវខូច ។

ខ) **អាស្ស៊រ៍** - អំឡុងពេលស្វ៉ឡាត់ ៤ រ៉ក់អាត់មុនថ្ងៃលិចជាពេលដាច់ខ្សែកសម្រាប់តែស្វ៉ឡាត់អាស្ស៊រ៍ទេ ។ បើអ្នកណាបំពេញស្វ៉ឡាត់ស៊្មុំស្វរ៍ក្នុងពេលនេះ ស្វ៉ឡាត់នោះត្រូវខូច ។

អំឡុងពេលក្នុងចន្លោះពេលស្វ៉ឡាត់ដាច់ខ្សែកទាំងពីរនេះជាពេលរួម សម្រាប់ស្វ៉ឡាត់ស៊្មុំស្វរ៍និងស្វ៉ឡាត់អាស្ស៊រ៍ ។

គ) **ម៉ាក់រីប** - អំឡុងពេលស្វ៉ឡាត់ ៣ រ៉ក់អាត់ក្រោយពេលថ្ងៃលិចជាពេលដាច់ខ្សែកសម្រាប់តែស្វ៉ឡាត់ម៉ាក់រីបទេ ។ បើអ្នកណាបំពេញស្វ៉ឡាត់អ៊ីស្ហាអ៍ក្នុងពេលនេះ ស្វ៉ឡាត់នោះត្រូវខូច ។

ឃ) **អ៊ីស្មារ៍** អំឡុងពេលស្វ៍ឡាត់ ៤ រ៉ក់អាត់មុនពាក់កណ្ដាលអធ្រាត្រជាពេលដាច់ខ្សែកសម្រាប់តែស្វ៍ឡាត់អ៊ីស្មារ៍ទេ ។ បើអ្នកណាបំពេញស្វ៍ឡាត់ម៉ាក់រីបក្នុងពេលនេះ ស្វ៍ឡាត់នោះត្រូវខូច ។

អំឡុងពេលក្នុងចន្លោះពេលស្វ៍ឡាត់ដាច់ខ្សែកទាំងពីរនេះ ជាពេលរួមសម្រាប់ស្វ៍ឡាត់ម៉ាក់រីបនិងស្វ៍ឡាត់អ៊ីស្មារ៍ ។

**មេរៀនទី ១២**

# ស៊ៅម៍(១) (សីលត្រណមអាហារ)

**សីលត្រណមអាហារ** មានន័យថាចៀសវាងអ្វីដែលផ្តាច់សីលត្រណម ចាប់ពីស៊ូប៊ហ៍ ស្វ៍ឌិក្ង (ព្រឹកមុនថ្ងៃរះពិតប្រាកដ) រហូតដល់ពេលម៉ាក់រិប (ពេលថ្ងៃលិច)។

## ផលប្រយោជន៍របស់ខែរ៉ម៉ាដូន

សម័យថ្ងៃមួយ ព្រះសាស្តាﷺបានសម្តែងធម៌ថា៖ "ប្រជារាស្ត្រអើយ ខែ (រ៉ម៉ាដូន) របស់អល់ឡោះហ្ទ៍ﷻមកដល់ហើយ ជាមួយព្រះមេត្តាធម៌និងសិរីសួស្តីរបស់ព្រះអង្គﷻ។ ខែនេះជាខែដែលប្រសើរលើសខែទាំងអស់សម្រាប់អល់ឡោះហ្ទ៍ﷻ។ ថ្ងៃរបស់ខែនេះជាថ្ងៃប្រសើរបំផុត យប់របស់ខែនេះជាយប់ប្រសើរបំផុត ម៉ោងរបស់ខែនេះជាម៉ោងប្រសើរបំផុត។ អល់ឡោះហ្ទ៍ﷻ អញ្ជើញអស់លោកក្នុងខែនេះ (មកកាន់សីលត្រណមអាហារនិងធ្វើនមស្ការ)។ ក្នុងខែនេះគេបានបើកឱកាសឲ្យអស់លោកទទួលបាននូវកិត្តិយសពីអល់ឡោះហ្ទ៍ﷻ ព្រះដ៏មានព្រះខន្តី។

ក្នុងអំឡុងខែនេះ បើអស់លោកកាន់សីលតមអាហារពិតប្រាកដ ដូចដែលគេបានដាក់បញ្ជាមកលើអស់លោកមែននោះ រាល់ខ្យល់ដកដង្ហើមចេញចូលរបស់អស់លោកនឹងបានមកនូវរង្វាន់នៃតាស់ប៊ិះហ្ង៍ ឯដំណេករបស់អស់លោកនឹងបានមកនូវរង្វាន់នៃការគោរពបូជា។ ទង្វើល្អរបស់អស់លោកនឹងត្រូវតបស្នងលើសពីថ្ងៃធម្មតា ឯការបួងសួង (ឌូអាអ៍) របស់អស់លោកនឹងអាចមានប្រសិទ្ធិភាពជាងសព្វដង។ ដូច្នេះ អស់លោកត្រូវបង្ហាញខ្លួនចំពោះអល់ឡោះហ្ទ៍ﷻដោយចិត្តបរិសុទ្ធឥតបាបចិត្ត។ ចូរអស់លោកបួងសួងអល់ឡោះហ្ទ៍ﷻឲ្យព្រះអង្គﷻប្រទានពរជ័យដល់អស់លោក ឲ្យអស់លោកបានកាន់សីលត្រណមតទៅទៀត ឲ្យអស់លោកបានសូត្រគួរអាន។

ការពិត បុគ្គលណាមិនបានទទួលព្រះខន្តីមេត្តាពីអល់ឡោះហ្ទ៍ﷻទេ អ្នកនោះអាប់ឱនហ្មងសៅ។ ពេលអស់លោកកាន់សីលត្រណម ចូរនឹកឃើញអាការឃ្លាននិងអាការស្រេកនៅថ្ងៃគីយ៉ាម៉ាត់ (ថ្ងៃជំនុំជម្រះ)។ ចូរដាក់ទានឲ្យជនក្រីក្រនិងអ្នកទ័លក្រ។

ចូរគោរពអ្នកចាស់ទុំរបស់អស់លោក ។
ចូរអាណិតអាសូរយុវជនរបស់អស់លោក ហើយចូររាក់ទាក់ជាមួយញាតិ ។ ចូរការពារអណ្ដាតអស់លោកពីសម្ដីឥតខ្លឹមសារ ចូរការពារភ្នែកអស់លោកពីអ្វីដែលត្រូវហាម ចូរការពារត្រចៀកអស់លោកពីអ្វីដែលមិនគប្បីត្រូវឮ ។"

**មេរៀនទី ១៣**

# ស្ងៅម៍(២) (សីលត្រណមអាហារ)

**អ្វីដែលផ្តាច់សីលត្រណមអាហារ**

១. បរិភោគ ។
២. ផឹក ។
៣. មុជក្បាលទាំងស្រុងក្នុងទឹក ឬ មុជទឹក ។
៤. ចង្អោរដោយចេតនា ។
៥. បណ្តោយឲ្យធូលីចូលដល់ក្នុងបំពង់ក ។

**សីលត្រណមអាហារមានច្រើនប្រភេទ**

**សីលត្រណមអាហារចាំបាច់(វ៉ាយ៊ីប)មួយចំនួន**

១. ខែរ៉ម៉ាដូន ។
២. កុ៏ដ្ធ៏ខែរ៉ម៉ាដូន ។
៣. ស្ងៅម៍កាហ្វ៉ហ្វារ៉ោះត្ហ៍ (كفارة) ឬព្រោះតែបានផ្អាកត្រណម ឬព្រោះតែមិនបានសម្រេច ។
៤. ស្ងៅម៍ដែលជាវ៉ាយ៊ីបបន្ទាប់ពីបានសច្ចា (نذر) បានស្បថ (قسم) បានធ្វើកិច្ចព្រមព្រៀង (عهد) ។
៥. ស្ងៅម៍កុ៏ដ្ធ៏របស់ឪពុក វ៉ាយ៊ីបលើកូនប្រុសបងគេ (ក្រោយពីឪពុកស្លាប់) ។

**សីលត្រណមអាហារស៊ូណាត់**

១. រាល់ថ្ងៃក្នុងខែរ៉យ៉ាប់និងក្នុងខែស្ងាក់បាន(شعبان) ឬតាមថ្ងៃណាដែលធ្វើទៅបាន ទោះបីមួយថ្ងៃក៏ដោយ ។
២. ថ្ងៃទី ១៣, ១៤ និង ១៥ រាល់ខែសុរិយគតិ ។

៣. ថ្ងៃទី ១៨ ខែ ស្ហ៊ុល-ហ៊្ជិយ្យ៉ាស្ហ (ذو الحجة - ថ្ងៃបុណ្យក៏ឌៀរ) ។
៤. ថ្ងៃទី ២៤ ខែ ស្ហ៊ុល-ហ៊្ជិយ្យ៉ាស្ហ (مباهلة - ថ្ងៃបុណ្យមូបាហ្វាឡាស្ហ) ។
៥. ថ្ងៃទី ២៤ ខែ រ៉យ៉ាប់ (មិអ្ររ៉ាជ្ជ)

**សីលត្រណមអាហារដែលត្រូវហាម**

១. កាន់ត្រណមពេលមានជម្ងឺ ។
២. ថ្ងៃទី ១ ខែ ស្ហៅវ៉ាល់ (شوّال - ថ្ងៃបុណ្យអាល់-ហ្វិត្រ) ។
៣. ថ្ងៃទី ១០ ខែ ស្ហ៊ុល-ហ៊្ជិយ្យ៉ាស្ហ (ថ្ងៃបុណ្យអាល់-ហ៊ាជ្ជ) ។

**សីលត្រណមអាហារដែលគប្បីចៀសវាង(ម៉ាក់រុះហ្វ)**

កាន់សីលត្រណមអាហារថ្ងៃទី ១០ ខែមូហ៊ារ៉ម(محرم) ជាម៉ាក់រុះហ្វ (ថ្ងៃអាស្ហ៊ូរ៉អ៍ عاشوراء) ។

**វ៉ាយីបពាក់ព័ន្ធនឹងសីលត្រណមអាហារ (លក្ខខ័ណ្ឌរបស់ស្ហៅម៍)**

មានលក្ខខ័ណ្ឌមួយចំនួនក្នុងការកាន់សីលត្រណមកាហារ គឺះ

១. មានសុខភាពល្អ ។
២. ជាអ៊ីស្លាម ។
៣. មិនធ្វើដំណើរទេនៅពេលស្ហ៊ុស្ហរ៍ ។
៤. មិនមានគ្រោះថ្នាក់ដោយសារជម្ងឺទេនៅពេលកាន់សីលត្រណមអាហារ ។

ប្រសិនបើអ្នកដំណើរត្រឡប់ទៅទីលំនៅវិញ ឬ មកដល់កន្លែងណាមួយដែលគេចង់ស្នាក់នៅ ១០ ថ្ងៃឬលើសពី ១០ ថ្ងៃ មុនពេលស្ហ៊ុស្ហរ៍ ហើយពុំបានធ្វើអ្វីមួយដែលបណ្តាលឲ្យដាច់ត្រណមនោះទេ អ្នកនោះត្រូវនៀតកាន់សីលត្រណមអាហារ សីលព្រណមរបស់អ្នកនោះនឹងមានសុពលភាព (គឺមិនខូចទេ) ។ ដូចគ្នាដែរ បើគេចាប់ផ្តើមធ្វើដំណើរក្រោយពេលស្ហ៊ុស្ហរ៍ សីលត្រណមថ្ងៃនោះនៅតែមានសុពលភាព ។

**ផលប្រយោជន៍របស់ខែពិសិដ្ឋរ៉ម៉ាដន**

"អល់ឡោះហ្វ៍﷿អឺយ នេះគឺខែរ៉ម៉ាដន ។ ក្នុងខែនេះឯងដែលព្រះអង្គ﷿បានចាត់បញ្ជូនគួរអានមក ជាមគ្គុទេសក៍ដឹកនាំសម្រាប់មនុស្ស ជាសញ្ញាជាក់ច្បាស់មួយសម្រាប់ញែកការពិតចេញពីវិរុទ្ធភាព ជាខែកាន់ត្រណមអាហារ ជាខែបំពេញការបួងសួង ជាខែសម្រាប់បែរមករកព្រះអង្គ﷿ និងជាខែសូមស្មារលាកំហុស ។ ជាខែអត់ឱនទោសនិងអនុគ្រោះលោះលា ។ ជាខែដែលមាន "យប់អាល់-ក្វូដ្ស៍" ដែលជាខែប្រសើរលើស ១០០០ ខែ ។ អល់ឡោះហ្វ៍﷿អឺយ សូមព្រះអង្គ﷿ព្រះរាជទានពជ័យសិរី សួស្តីដល់មូហ៊ាំម៉ាដ្ទ៍ﷺ ព្រមទាំងព្រះរាជកុលដ្ឋាន﵈របស់ព្រះអង្គﷺផង ។ សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំជាខ្ញុំបានទំនេរដើម្បីគោរពបូជាព្រះអង្គ﷿ និងសូត្រព្រះគម្ពីរ ។"

ប្រយោគខាងលើនេះបញ្ជាក់ថា ក្នុងចំណោមសិរីសួស្តីរបស់ខែនេះមាន៖ គួរអានយប់អាល់-ក្វូដ្ស៍ ការសូមស្មារលាទោសពៃរ៍ និងការយោគយល់និងការលើកលែងទោសទៅវិញទៅមក ។

គ្រប់ទង្វើ ល្អក្តីអាក្រក់ក្តី មានទម្ងន់ជាងសព្វដងក្នុងខែនេះ ។ ដូច្នេះ ការដាក់ទានដែលជាទង្វើល្អរាល់ដងនោះ ក្នុងខែនេះ នឹងមានទម្ងន់ច្រើនជាង ។

ឯទង្វើអាក្រក់នោះ វាអាក្រក់គ្រប់ពេល តែវាអាក្រក់ជាងគេក្នុងខែរ៉ម៉ាដន ។ សូត្រគួរអានជាទង្វើគួរឲ្យសរសើរទូទាំងឆ្នាំ តែក្នុងអំឡុងពេលកាន់សីលត្រណមអាហារមានន័យខ្ពង់ខ្ពស់ជាងសព្វដង ។

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "សព្វអ្វីៗសុទ្ធតែមាននិទាឃៈរដូវរបស់វា ឯនិទាឃៈរដូវរបស់គួរអានគឺខែរ៉ម៉ាដន ។"

**មេរៀនទី ១៤**

# អាំរ៍ ប៊ិល-ម៉ាក់រូហ្វ

وَلۡتَكُن مِّنكُمۡ أُمَّةٞ يَدۡعُونَ إِلَى ٱلۡخَيۡرِ وَيَأۡمُرُونَ بِٱلۡمَعۡرُوفِ وَيَنۡهَوۡنَ عَنِ ٱلۡمُنكَرِۚ وَأُوْلَٰٓئِكَ هُمُ ٱلۡمُفۡلِحُونَ

*"ចូរឲ្យមាននៅក្នុងចំណោមពួកអ្នក នូវសហគមន៍មួយដែលហៅទៅរកសេចក្ដីល្អប្រពៃ បង្គាប់ឲ្យប្រព្រឹត្តល្អ[តាមព្រះគម្ពីរអល់ឡោះហ្វ៍និងតាមព្រះសាស្ដាព្រះអង្គ] ហាមប្រព្រឹត្តអាក្រក់ (គឺហាមអ្វីដែលអល់ឡោះហ្វ៍ហាម) ។ ជនទាំងនោះជាជនដែលនឹងបាននូវជ័យជំនះ [បានដល់សុខុមាលភាពនៃឋានសួគ៌] ។" (ស៊ី. ៣, អា. ១០៤)*

នេះគឺសសរទ្រូងអ៊ីស្លាមទី ៧ មានន័យថាបង្គាប់ឲ្យធ្វើល្អ ។ បើបុគ្គលណាមិនប្រតិបត្តិតាមកាតព្វកិច្ចដែលអល់ឡោះហ្វ៍ដាក់មកទេ យើងចាំបាច់ត្រូវណែនាំបុគ្គលនោះនៅលើមាគ៌ាត្រឹមត្រូវ ដោយសង្ឃឹមថាបុគ្គលនោះនឹងដឹកនាំខ្លួនតាមការចង្អុលណែនាំដែលយើងបានបង្ហាញគេ ។

នេះគឺសាខាមួយសំខាន់ណាស់ក្នុងសាសនាអ៊ីស្លាម ។ អ្វីៗដែលត្រូវអល់ឡោះហ្វ៍ដាក់មកជាបញ្ញាហៅថាម៉ាក់រូហ្វ មានន័យថាកុសល (គឺសេចក្ដីល្អ) ។ ឧទាហរណ៍ ស្ម័ឡាត្ទ សីលត្រណមអាហារ យុមស៍ ស្ញាកាត្ទ និងពង្រឹងគ្រឹះសាសនាអ៊ីស្លាម ។ ត្រូវបូកបញ្ចូលក្នុងឧទាហរណ៍នេះផងដែរនូវអ្វីដែលជាអនុសាសន៍ ដូចជាផ្ដល់អាហារនិងទទួលភ្ញៀវ បង្ហាត់បង្រៀនសិក្ខាបទអ៊ីស្លាម សីលធម៌ (أخلاق) និងមានចរិយាគប្បី ។

បង្គាប់បុគ្គលឲ្យធ្វើល្អលើកដំបូងជាវ៉ាយ៉ិប លើកទីពីរជាស៊ូណាត្ទ ។

អាំរ៍ ប៊ិល-ម៉ាក់រូហ្វទៅជាវ៉ាយ៉ិបអាស្រ័យលើបួនលក្ខខ័ណ្ឌ គឺ៖

១. អ្នកដឹងថាអ្វីល្អ អ្វីអាក្រក់ ។
២. អ្នកសង្ឃឹមថាគេនឹងប្រតិបត្តិតាមយោបល់ដែលអ្នកឲ្យទៅគេ ។
៣. បុគ្គលដែលអ្នកឲ្យយោបល់នោះចចេសប្រព្រឹត្តខុស ។
៤. អ្នកដឹងថាពេលអ្នកឲ្យយោបល់ទៅគេ អ្នកនឹងមិនរងទុក្ខដោយសារយោបល់នោះទេ ។

ក៏ប៉ុន្តែ កាលណាជំនឿដើមរបស់មុស្លីមជួបប្រទះគ្រោះថ្នាក់ ឬសាសនាអ៊ីស្លាមត្រូវរង្គើ (ឧទាហរណ៍ ពេលដែលស្រុកទេសចង់ផ្លាស់ប្តូរជំនឿរបស់ប្រជារាស្ត្រ ឬជួយជម្រុញឲ្យផឹកស្រានិងលេងល្បែងស៊ីសង) ពេលនោះម្នាក់ៗចាំបាច់ត្រូវបង្គាប់ឲ្យប្រព្រឹត្តិល្អ និងណែនាំកុំឲ្យប្រព្រឹត្តអំពើហាមប្រាម ទោះបីធ្វើបែបនេះនឹងត្រូវរងទុក្ខដោយសារទង្វើនេះក៏ដោយ ។

**មេរៀនទី ១៥**

# ណាស់យី អាន់និល មុនការ (نهى عن المنكر)

كُنتُمۡ خَيۡرَ أُمَّةٍ أُخۡرِجَتۡ لِلنَّاسِ تَأۡمُرُونَ بِٱلۡمَعۡرُوفِ وَتَنۡهَوۡنَ عَنِ ٱلۡمُنكَرِ وَتُؤۡمِنُونَ بِٱللَّهِ

*"[ឱបណ្ដាអ្នកមានសទ្ធាជ្រះថ្លានិងមានព្រហ្មចារិយធម៌អើយ] ពួកអ្នកជាសហគមន៍ល្អបំផុតដែលបានលេចឡើងសម្រាប់បណ្ដាមនុស្ស ។ ពួកអ្នកបង្គាប់ឲ្យធ្វើល្អ [តាមព្រះរាជក្រឹត្យដែលអល់ឡោះហ្ទ៍ដាក់មក] ពួកអ្នកហាមប្រព្រឹត្តអំពើអាក្រក់ ពួកអ្នកមានសទ្ធាចំពោះអល់ឡោះហ្ទ៍ ។" (ស៊ៈ ៣, អា. ១១០)*

នេះគឺសសរទ្រូងអ៊ីស្លាមទី ៨ មានន័យថាហាមធ្វើអំពើណាដែលហ្ារ៉ាំ ។ យើងត្រូវប្រាប់អ្នកណាដែលធ្វើអំពើដែលអល់ឡោះហ្ទ៍ហាមឲ្យចៀសវាងធ្វើអំពើនោះ ដោយសង្ឃឹមថាបុគ្គលនោះនឹងធ្វើតាមការចង្អុលណែនាំនេះ ។

"មុនការ" មានន័យថាអ្វីៗដែលត្រូវហាមក្នុងសាសនាអ៊ីស្លាម ដូចជា ផឹកសុរា លេងល្បែងអ៊ីសង ស្ដាប់តន្ត្រី បរិភោគសាច់ជ្រូក ។ល ។

ដូច "អាំរ៍ ប៊ិល-ម៉ាក់រូហ្វ" ដែរ អនុវត្តិ "ណាស់យី អាន់នីល មុនការ" លើកដំបូងជាវ៉ាយ៉ិប លើកទីពីរជាស៊ូណាត់ ។

មានបួនតំណាក់ការ ដើម្បីធ្វើឲ្យគេលែងហ៊ានប្រព្រឹត្តទង្វើទាំងនេះដែលសាសនាអ៊ីស្លាមហាម គឺៈ

១. ផ្ចត់អារម្មណ៍របស់បុគ្គលដែលអ្នកឲ្យយោបល់ ។
២. បង្ហាញទឹកមុខស្អប់ខ្ពើមចំពោះទង្វើរបស់បុគ្គល ដែលប្រព្រឹត្តអំពើដែលត្រូវហាម ។
៣. តាមរយៈសម្ដី ឬយោបល់ ឬបម្រាម ឬតាមរយៈសម្ដីខ្លាំង ។

៤. តាមរយៈកម្លាំងបាយដើម្បីបញ្ឈប់ទង្វើអាក្រក់ កុំឲ្យតែបុគ្គលនោះរងនូវសេចក្តីឈឺចាប់ ។ បុគ្គលនោះមិនត្រូវរងរបួសទេ ។

បុគ្គលដែលអនុវត្តិ "អាំរ៍ ប៊ិល-ម៉ាក្រ៉ូហ្វ" និង "ណាស្ហ៍យី អ៊ុនីល មុនការ" ជាបុគ្គលដែលអល់ឡោះហ្វ៍វាយតម្លៃខ្ពស់ ។ ព្រះអង្គទុកដាក់ពួកគេក្នុងចំណោមបាវបម្រើព្រះអង្គដែលមានជោគជ័យ ។

**មេរៀនទី ១៦**

# តាវ៉ាល់ឡា(تولّى)

قُلْ إِن كُنتُمْ تُحِبُّونَ ٱللَّهَ فَٱتَّبِعُونِى يُحْبِبْكُمُ ٱللَّهُ وَيَغْفِرْ لَكُمْ ذُنُوبَكُمْ ۗ وَٱللَّهُ غَفُورٌ رَّحِيمٌ

*[សាស្តាអ៊ីយ] ចូរអ្នកថ្លែង[ប្រាប់បណ្តាមនុស្ស]ថា៖ "បើអស់លោកស្រឡាញ់អល់ឡោះហ្វចូរតាមខ្ញុំ ។ អល់ឡោះហ្វនឹងសព្វព្រះហឫទ័យអស់លោក ព្រះអង្គនឹងអត់ឱនឲ្យអស់លោកដែលបានសាងបាប ។ អល់ឡោះហ្វខមាទោស ព្រះអង្គមានព្រះមេត្តាករុណាប្រណី ។" (ស៊ិ. ៣, អា. ៣១)*

តាវ៉ាល់ឡាជាសសរទ្រូងអ៊ីស្លាមទី ៩ មានន័យថា ស្រឡាញ់និងតាមសិក្ខាបទរបស់អាស្ហ់លុល-បៃត៍ﷺ ។

គេបកប្រែតាវ៉ាល់ឡានៅក្នុងគម្ពីរគួរអានថា "ទិសដៅដែលមុស្លីមបែរទៅរកដើម្បីដឹកនាំខ្លួន" ។

ព្រះមហាគម្ពីរគួរអានចែងថា៖

وَلِكُلٍّ وِجْهَةٌ هُوَ مُوَلِّيهَا ۖ فَٱسْتَبِقُوا۟ ٱلْخَيْرَٰتِ ۚ أَيْنَ مَا تَكُونُوا۟ يَأْتِ بِكُمُ ٱللَّهُ جَمِيعًا ۚ إِنَّ ٱللَّهَ عَلَىٰ كُلِّ شَىْءٍ قَدِيرٌ ﴿١٤٨﴾

*"ម្នាក់ៗមានគោលដៅមួយសម្រាប់បែរទៅរក ។ ដូច្នេះអ្នកទាំងឡាយចូររវៀសរវៃសាងអំពើល្អ ។ ទោះជាពួកអ្នកនៅទិសទីតំបន់ណាក៏ដោយ អល់ឡោះហ្វនឹងនាំពួកអ្នកទាំងអស់គ្នាមកវិញ ។ ពិតណាស់ អល់ឡោះហ្វមានសព្វានុភាពលើសព្វសារពើ ។"*(ស៊ិ. ២, អា. ១៤៨)

សម្រាប់អស់មុស្លីម អាស្ហ់លុល-បៃត៍ﷺជាទិសដៅដែលត្រូវបែរទៅរកដើម្បីដឹកនាំខ្លួននិងដើម្បីប្រព្រឹត្តអំពើល្អ ។

ក៏ប៉ុន្តែសេចក្តីស្រឡាញ់នោះ គេមិនព្រមទទួលយកយ៉ាងពិតប្រាកដទេទោះបីនៅក្នុងលោកនេះក៏ដោយ ។ បង្ហាញនូវសេចក្តីស្រឡាញ់ចំពោះប្រទេសជាតិយើងដែលជាមាតុភូមិយើងនោះ យើងមិនត្រឹមតែសច្ចាថានឹងស្មោះត្រង់ប៉ុណ្ណោះទេ យើងព្រមតាមច្បាប់និងបទបញ្ជារបស់ប្រទេសជាតិដែរ ។

ដូចគ្នាដែរ តាវ៉ាល់ឡាចង់ឲ្យយើងមិនត្រឹមតែស្រឡាញ់អាស្វ៉លុល-បៃត៍ប៉ុណ្ណោះទេ ថែមទាំងឲ្យយើងស្មោះត្រង់ចំពោះអាស្វ៉លុល-បៃត៍ ហើយព្រមតាមគំរូអាស្វ៉លុល-បៃត៍ផង ។

**មេរៀនទី ១៧**

# តាបារ៉ (تبرأ)

إِنَّ ٱلَّذِينَ يُؤْذُونَ ٱللَّهَ وَرَسُولَهُۥ لَعَنَهُمُ ٱللَّهُ فِى ٱلدُّنْيَا وَٱلْـَٔاخِرَةِ وَأَعَدَّ لَهُمْ عَذَابًا مُّهِينًا

*"ជនទាំងឡាយណាដែលប្រមាថអល់ឡោះហ្វ៍និងព្រះសាស្ដាព្រះអង្គ អល់ឡោះហ្វ៍ដាក់បណ្ដាសាជនទាំងនោះក្នុងលោកនេះនិងលោកមុខ ។ ព្រះអង្គបានត្រៀមការដាក់ទោសដ៏ទាបថោកសម្រាប់ជនទាំងនោះ ។" (ស៊. ៣៣, អា. ៥៧)*

នេះជាសសរទ្រូងអ៊ីស្លាមទី ១០ ។ មានន័យថាចេញមុខប្រឆាំងជនទាំងឡាយណាដែលប្រព្រឹត្តអាក្រក់លើអស់បាវបម្រើសច្ចការីរបស់អល់ឡោះហ្វ៍ ។ ពេលណាយើងចៀសឆ្ងាយពីពួកនោះ ពេលនោះបានសេចក្ដីថាយើងមិនយល់ស្របតាមអំពើអាក្រក់របស់ពួកនោះទេ ។

"តាបារ៉" មានន័យថាចៀសឆ្ងាយពីជនអាក្រក់ ។ បើយើងមើលទៅឯពិភពលោកយើងនឹងឃើញថាទាំងបុគ្គល ទាំងរដ្ឋនានាប្រកាសបដិសេធអំពើអាក្រក់ ហើយចៀសចេញពីជនអាក្រក់ ។ ក្នុងករណីអំពើអាក្រក់ដែលមានទំហំវិសេសវិសាល គេសង្ឃឹមថារដ្ឋដែលមានអារ្យធម៌ទាំងអស់នឹងថ្កោលទោសអំពើអាក្រក់ ។

ដូចគ្នាដែរ សង្ឃឹមថាមុស្លីមគ្រប់រូបថ្កោលទោសអំពើអាក្រក់គ្រប់វេលាដែលបានប្រព្រឹត្តនៅក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម ។ បើពួកគេមិនធ្វើទេ ពួកគេត្រូវចាត់ទុកជាបក្សពួករបស់ពួកប្រព្រឹត្តអាក្រក់ ។

នៅក្នុងព្រះគម្ពីរគួរអាន អល់ឡោះហ្វ៍ហាមយ៉ាងច្បាស់ថាមិនឲ្យចងមិត្តភាពជាមួយជនណាដែលជាសត្រូវរបស់អល់ឡោះហ្វ៍និងមុស្លីមទេ ។

## លំហាត់ ១

ចូរជ្រើសរើសយកចម្លើយមួយ ហើយគូសជុំវិញចម្លើយនោះ ។

១. មាន ១០ ទង្វើវ៉ាយ៉ិបក្នុងស្ស៊ូឡាត្ត ។ ទង្វើដែលមិនមែនជាវ៉ាយ៉ិប រុកន៍ (រូកុនវ៉ាយ៉ីប) ហើយក៏មិនមែនវ៉ាយ៉ិប កុយ៉រ៉ រុកនី (រូកុនវ៉ាយ៉ិបអនុលោម) នោះគឺ ៖

ក. តាក់បីរ៉ទុល អ៊ិះហ្រ៉ាម ។

ខ. នៀត ។

គ. មូវ៉ាឡាត់ ។

ឃ. គូនូត ។

២. ក្នុងចំណោមវាក្យសម្ព័ន្ធខាងក្រោមនេះ តើវាក្យសម្ព័នមួយណាដែលជាន័យត្រឹមត្រូវជាងគេរបស់ "វ៉ាយ៉ិប រុកន៍" ។

ក) ប៉ែកនានារបស់ស្ស៊ូឡាត្តដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយដោយចេតនា ធ្វើឲ្យស្ស៊ូឡាត្តមោឃៈ ។

ខ) ប៉ែកនានារបស់ស្ស៊ូឡាត្តដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយដោយចេតនា មិនធ្វើឲ្យស្ស៊ូឡាត្តមោឃៈទេ ។

គ) ប៉ែកនានារបស់ស្ស៊ូឡាត្តដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយដោយចេតនា ធ្វើឲ្យស្ស៊ូឡាត្តត្រឹមត្រូវ ។

ឃ) មិនមានវាក្យសម្ព័នមួយណាត្រឹមត្រូវទេ ។

៣. ក្នុងពេលបំពេញស្ស៊ូឡាត្ត វ៉ាយ៉ីបឲ្យ ៖

ក) ថ្ងាសនិងម្រាមជើងត្រូវដាក់លើកម្ពស់ខុសគ្នា ពេលវាប៉ះដី ។

ខ) ថ្ងាសនិងម្រាមជើងត្រូវដាក់លើកម្ពស់ស្មើគ្នា ពេលវាប៉ះដី ។

គ) ថ្ងាសត្រូវខ្ពស់ជាងម្រាមជើង ។

ឃ) មិនមានវាក្យសម្ព័នមួយណាត្រឹមត្រូវទេ ។

៤. ប្រសិនបើបុគ្គលណាមិនអាចសាច់ដ្ឋាស់បានដោយសារជម្ងឺ ឬដោយសារមូលហេតុផ្សេង បុគ្គលនោះត្រូវសាច់ដ្ឋាស់តាមលំដាប់ដូចតទៅ គឺះ

ក) បន្ទាបខ្លួនតាមសមត្ថភាពដែលអាចធ្វើបាន បន្ទាប់មក បុគ្គលនោះត្រូវសាច់ដ្ឋាស់ ដោយកម្រើកប្រអប់ដៃឬប៉ែកផ្សេងទៀតរបស់រូបកាយ ។

ខ) សាច់ដ្ឋាស់ដោយឱនក្បាល ។

គ) សាច់ដ្ឋាស់ដោយបិទភ្នែក ។

ឃ) វាក្យសម្ព័ន្ធទាំងអស់សុទ្ធតែត្រឹមត្រូវ ។

៥. ប្រសិនបើបុគ្គលណាភ្លេចសាច់ដ្ឋាស់ ស្វ៍ឡាត់របស់បុគ្គលនោះត្រឹមត្រូវបើបុគ្គលនោះ ៖

ក) នឹកឃើញវិញមុនរុគុអ៍ខាងមុខ ។

ខ) នឹកឃើញវិញក្រោយពីបានបំពេញស្វ៍ឡាត់ចប់ ។

គ) នឹកឃើញវិញមុនសាច់ដ្ឋាស់ក្នុងរ៉ក់អាត់ខាងមុខ ។

ឃ) មិនមានវាក្យសម្ព័នមួយណាត្រឹមត្រូវទេ ។

៦. វាក្យសម្ព័នទាំងអស់ខាងក្រោមនេះ ជាទង្វើមុសតាហ្ចាប់ទាំងអស់ក្នុងសាច្ចុំដ្វាស្ង លើក លែងតែ ៖

ក) ដាក់ថ្វាសលើដី (កម្រាល) ។

ខ) សម្លឹងទៅឯច្រមុះ ។

គ) ដាក់ជង្គង់លើដី ។

ឃ) ថាតាក់បៀរមុនសាច្ចុំដ្វាស្ង ។

៧. តាស្ហាស្ហ៊ុហ្វ៊ុដ្ធមានន័យថា ៖

ក) អង្គុយ ។
ខ) ប្តេជ្ញាចំពោះអល់ឡោះហ្វ៍ ។
គ) សូត្រស្វ៊ពោះត៌្ត អាល់-ហ្វាំដ្ធ៌ និង ស្វ៊ពោះត៌្ត អាល់-អ៊ិះខ្លាស់ ។
ឃ) មិនមានវាក្យសម្ព័នមួយណាត្រឹមត្រូវទេ ។

៨ វ៉ាឃ្ចិប កុយរ៉ រុកនី មានន័យថា ៖

ក) ប៉ែកនានារបស់ស្វ៍ឡាត្ត៍ដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយ ដោយចេតនា ធ្វើឲ្យស្វ៍ឡាត្ត៍មោឃៈ ។
ខ) ប៉ែកនានារបស់ស្វ៍ឡាត្ត៍ដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយដោយចេតនា មិនធ្វើឲ្យស្វ៍ឡាត្ត៍មោឃៈទេ ។
គ) ប៉ែកនានារបស់ស្វ៍ឡាត្ត៍ដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយដោយអចេតនា ធ្វើឲ្យស្វ៍ឡាត្ត៍មោឃៈ ។
ឃ) មិនមានវាក្យសម្ព័នមួយណាត្រឹមត្រូវទេ ។

៩ មានទង្វើវ៉ាឃ្ចិបប្រាំក្នុងសាច្ចុំដ្វាស្ង ។ វាក្យសម្ព័នដែលមិនមែនជាវ៉ាឃ្ចិបគឺ ៖

ក) រូបកាយប្រាំពីរប៉ែកត្រូវប៉ះដី (កម្រាល) ។
ខ) ត្រូវនៅនឹងមួយកន្លែងពេលសូត្រស៊ីករ៍សាច់ដ្ហាស្ញ ។
គ) ត្រូវសូត្រជាភាសាអារ៉ាប់ ។
ឃ) មើលទៅឯច្រមុះ ។

១០ ប្រសើរជាងគេគឺសាច់ដ្ហាស្ញលើដុំដីដែលមកពី ហ៊ារ៉ម អ៊ីម៉ាំ ហ៊្វសែន៍ﷺ នៅឯការបាឡា ។ គេហៅដុំដីនោះថា៖

ក) ទួរបាទូល ហ៊្វសៃនីយ៉ាស្ញ ។
ខ) ខាក់ ស៊្វីហ្វាអ៊្ញ ។
គ) តាស់បិះហ៍ ហ្វាទីម៉ាស្ញ ។
ឃ) វាក្យសម្ព័នពីរ ក) និង ខ) ។

## លំហាត់ ២

វាក្យសម្ព័នខាងក្រោមនេះត្រូវឬខុស ។ ត្រូវសរសេរថា "ត" ខុសសរសេរថា "ខ" នៅលើគំនូស ។

១. ហ៊ារ៉ាំសាច់ដ្ហាស្ញដាក់អ្វីផ្សេងពីអល់ឡោះហ៍ ។______
២. ស៊ូណាត់ឲ្យសូត្រគួរអានពេលសាច់ដ្ហាស្ញ______
៣. មិនអាចសាច់ដ្ហាស្ញលើដីឬខ្សាច់បានទេព្រោះថ្ងាសមិននឹង ។______
៤. គេអនុញ្ញាតឲ្យយើងសាច់ដ្ហាស្ញលើសំបកផ្លែឈើបាន ។______
៥. ពេលចុះសាច់ដ្ហាស្ញ បុរសគប្បីដាក់ជង្គង់លើដីជាមុន ។______
៦. ពេលចុះសាច់ដ្ហាស្ញ នារីគប្បីដាក់ប្រអប់ដៃលើដីមុនជង្គង់ ។_____
៧. មិនអនុញ្ញាតឲ្យអ្នកសាច់ដ្ហាស្ញលើអាវយឺតអ្នកទេ ។_____
៨. មិនអនុញ្ញាតឲ្យអ្នកសាច់ដ្ហាស្ញលើសំលៀកបំពាក់អ្នកទេ ទោះបីអ្នកមិនមានអ្វីដែលគេអនុញ្ញាតឲ្យសាច់ដ្ហាស្ញលើក៏ដោយ ។_____
៩. ប៊ីប៊ីហ្វាទីម៉ាស្ញﷺសូត្រតាស់បិះហ៍មុនគេ ។_____

១០. ដាក់ក្បាលយើងលើដីជាការរំលឹកដល់ពលីកម្មជីវិតរបស់អ៊ីម៉ាំហ៊្សៃសែន عليه السلام ។___

## លំហាត់ ៣

១. ចូរបំពេញចន្លោះទទេដោយពាក្យខាងក្រោមនេះ គឺៈ

នៅស្ងៀម, វ៉ាយ៉ិប, ២, ចុងក្រោយ, អារ៉ាប់, ជំនឿ, ធ្វើសាក្សី, កុយ៉ររ៍, អង្គុយ, មូវ៉ាឡាត់

តាស្ហាស់ហ្ហ៊ុដមានន័យថា______ ។ គេសូត្រតាស្ហាស់ហ្ហ៊ុដក្នុងរ៉ក់អាត់ ទី______និង ក្នុងរ៉ក់អាត់__________ ។ តាស្ហាស់ហ្ហ៊ុដជាវ៉ាយ៉ិប______រុកន៍ក្នុងស្វ៉ឡាត់ ។ ត្រូវសូត្រតាស្ហាស់ហ្ហ៊ុដក្នុងពេលដែលអ្នក______ ។ អ្នកត្រូវតែ__________មិនកម្រើកខ្លួនទេក្នុងពេលនោះ ។ ត្រូវតែសូត្រជាភាសា______ ហើយត្រូវមាននិរន្តរភាព នេះគឺ________ ។ តាស្ហាស់ហ្ហ៊ុដជាសេចក្តីសង្ខេបរបស់______យើង ។

២. ចូរសរសេររបៀបសូត្រតាស្ហាស់ហ្ហ៊ុដ វ៉ាយ៉ិប និង សូណាត់ដែលបានសិក្សារួចមកហើយ ។ ចូរផាត់ព័ណ៌បៃតងត្រង់កន្លែងសូត្រស៊ូណាត់ ព័ណ៌ក្រហមត្រង់កន្លែងសូត្រវ៉ាយ៉ិប ។ ចូរសរសេរសម្រាយរបស់តាស្ហាស់ហ្ហ៊ុដ ។

៣. ចូរសរសេររបៀបសូត្រសាឡាម ។ ចូរបញ្ជាក់សាឡាមស៊ូណាត់ និង សាឡាមវ៉ាយ៉ិប ។

៤. សាឡាមជាទង្វើចុងក្រោយក្នុងស្វ៉ឡាត់ ។ ពេលណាអ្នកសូត្រសាឡាម អ្នក________ស្វ៉ឡាត់របស់អ្នក ។ អ្វីៗដែលត្រូវហាមសម្រាប់អ្នកនឹងទៅជា_________សម្រាប់អ្នកពេលនោះ ។ សូត្រតាក់បៀរ____ដងជាមុសតាហ្វាប់ក្រោយពីបានសូត្រសាឡាម ។ សាឡាមជាការរំលឹកនូវ_______ក្នុងសាសនាអ៊ីស្លាម ។

៥. ចូរសរសេរសម្រាយរបស់សាឡាម ។

## លំហាត់ ៤

១. ទង្វើភាគច្រើន ឬទាំងអស់តែម្តងក៏អាចថាបាន ត្រូវប្រព្រឹត្តទៅតាមលំដាប់ត្រឹមត្រូវ គេហៅរបៀបធ្វើនេះថា_______ ។ និរន្តរភាពនិងភាពខ្ជាប់ខ្ជួនក្នុងទង្វើនិងក្នុងការសូត្រជាកត្តាសំខាន់ដែរ ដែលគេហៅថា_______ ។

២. ការទីបនិងមូវ៉ាឡាត់ធ្វើឲ្យមុស្លីមទៅជាអ្នកមាន________________ ។

៣. តាកុំគ្វីបាត់មានន័យថា______និង_______ ។ ដែលគេសូត្រក្រោយស្វ៍ឡាត់ ។ តាស់ប៊ិះហ្វដែលគេស្គាល់ជាងគេគឺតាស់ប៊ិះហ្វរបស់ប៊ីប៊ី ហ្វាទីម៉ាស់ ﷺ ដែលរួមមានបីឃ្លាខ្លីៗ គឺ៖

___________________________ សូត្រ___ដង ។
___________________________ សូត្រ___ដង ។
___________________________ សូត្រ___ដង ។

## លំហាត់ ៥

ចូរអានអត្ថបទខាងក្រោមនេះ ហើយចូរអធិប្បាយថាហេតុអ្វីស្វ៍ឡាត់របស់ត៍លិបត្រូវមោឃៈ ដោយគូសពីខាងក្រោមប៉ែកនោះដែលធ្វើឲ្យស្វ៍ឡាត់មោឃៈ ។

ត៍លិបមកពីសាលារៀនវិញម៉ោងប្រមាណ ១៥:៤៥ ។ ដោយដឹងថាស្វ៍ឡាត់នឹងទៅជាក៏ឌ្ធ ម៉ោង ១៦:០០ វាក៏បានចាប់ផ្តើមបំពេញស្វ៍ឡាត់យ៉ាងលឿន ហើយដូចសព្វដងដែរ វាមិនអាចតាំងស្មារតីឲ្យបានមាំមួនទេក្នុងពេលស្វ៍ឡាត់ ។ វាគិតទៅដល់អ្វីៗដែលវាបានធ្វើក្នុងថ្ងៃនោះ ដូចជាការប្រកួតបាល់ទាត់ដែលវាឈ្នះនៅឯសាលារៀនពេលសម្រាក, ពេលវាកុហកគ្រូវាថា(ដោយអះអាងថាវាបានធ្វើបាត់សន្លឹកក្រដាស់លំហាត់) ហើយក៏បានភ្លេចទៅ ។ វាបានសើចក្នុងរ៉ក់អាត់ទីមួយព្រមនឹងសូត្រ ។ ពេលងើបឡើងពីរូគុអ៊ុំមកគ្វីយ៉ាម វានឹកឃើញ ពេលដែលវាបានទាត់ចូលកូល វាក៏បានស្រែកឡើងថា "កូល !" ហើយលោតឡើងមុនបំពេញស្វ៍ឡាត់បន្តដោយចុះទៅបំពេញសាច់ដ្ញាស់ ។ ម្តាយវាបានឃើញស្វ៍ឡាត់ចម្លែកនេះដោយចៃដន់គាត់បានបញ្ឈប់វាភ្លាម បានស្តីបន្ទោសវា បានដាក់ទណ្ឌកម្មវាដោយហាមវាលេង

កីឡាគ្រប់ប្រភេទអស់ពីរសប្តាហ៍ ។ គាត់បានឲ្យវាបំពេញស្វ៊ីឡាត្ត៉ុសាថ្មី ។ វាក៏បានបំពេញស្វ៊ីឡាត្ត៉ុម្តងទៀត សូត្រអាល់-ហ្វាំដ៉ុព្រមទាំងយំជាប់ ។

## លំហាត់ ៦

មិត្តមុស្លីម ស៊ុន្នីរបស់អ្នកបានបបួលអ្នកទៅលេងម៉ាស់ឃ្វីដជិតខាងដើម្បីនឹងស្វែងយល់គ្នាទៅវិញទៅមក ។ នៅពេលដើរមើលគេបានសូមឲ្យអ្នកចូលរួមក្នុងស្វ៊ីឡាត្ត៉ុឃ្ហុមអ៊ុស្ហ នៅពេលស្វ៊ីឡាត្ត៉ុអ៊ុស្ហ៍រ ។ អ្នកបានបំពេញស្វ៊ីឡាត្ត៉ុអ៊ុស្ហ៍រជាមួយស្វ៊ីឡាត្ត៉ុស្ហ៊ុស្ហរ៍រួចហើយ ។ ចូររលឹកឡើងវិញថាពួកមុស្លីមស៊ុន្នីបំពេញស្វ៊ីឡាត្ត៉ុស្ហ៊ុស្ហរ៍និងអ៊ុស្ហ៍របែកគ្នា ។

អ្នកមិនដឹងនិយាយថាអ្វី មិនដឹងធ្វើយ៉ាងណា អ្នកបារម្ភព្រោះអ្នកបានបំពេញស្វ៊ីឡាត្ត៉ុស្ហ៊ុស្ហរ៍រួចហើយ ។ ពួកមុស្លីមស៊ុន្នីថា "អាមីន" ក្រោយអាល់-ហ្វាំដ៉ុ ឱបដៃពេលបំពេញស្វ៊ីឡាត្ត៉ុ ។ តើអ្នកនឹងធ្វើយ៉ាងណា ?

## លំហាត់ ៧

តើអ្នកធ្វើយ៉ាងណាក្នុងស្ថានការណ៍ខាងក្រោមនេះ គឺៈ

១. អ្នកធ្វើដំណើរតាមយន្តហោះ អ្នកចង់បំពេញស្វ៊ីឡាត្ត៉ុ ។

២. អ្នកធ្វើដំណើរហើយអ្នកចង់បំពេញស្វ៊ីឡាត្ត៉ុ ។ ខ្លួនអ្នកនិងសំលៀកបំពាក់អ្នកណាឃ្វីស (ព្រោះបានចូលបង្គន់ហើយមិនមានទឹក) ។ មិនមានមធ្យោបាយជម្រះទេ ឯពេលវេលាក៏កំពុងតែចូលដល់ពេលក្ហ៊ុដ្ហ៍ ។

៣. មិត្តអ្នកតែងតែបំពេញស្វ៊ីឡាត្ត៉ុស្ហ៊ុបហ្វ៍ក្ហ៊ុដ្ហ៍ ព្រោះគេគិតថាស្វ៊ីឡាត្ត៉ុស្ហ៊ុបហ្វ៍មានតែពីររ៉ក់អ៊ុត្ត៉ុ វាមិនសំខាន់ទេ ។

៤. ម៉ោង ១៦:៣០ ជាម៉ោងក្ហ៊ុដ្ហ៍ ។ មិត្តអ្នកបបួលអ្នកមើលទូរទស្សន៍ ហើយនឹង

បំពេញស្វ៍ឡាត់នៅម៉ោង ១៦:១៥ ព្រោះពុំមានតារាងមើលម៉ោងឲ្យជាក់ច្បាស់ ទេ ហើយនៅមានពេលគ្រប់គ្រាន់មុនដល់ពេលក៏ផ្ជិ ។

## លំហាត់ ៨

ចូរបំពេញចន្លោះទទេ ។

១. បុគ្គលណាដែលចាត់ទុកស្វ៍ឡាត់ជាអ្វីមួយធម្មតា មិនធំដុំ បុគ្គលនោះដូចបុគ្គលដែល មិនបានបរិច្ចាគ______ហើយសមតែទទួលរងនូវទារុណកម្មក្នុង_____ ។ (ព្រះសាស្តាﷺ)

២. ស្វ៍ឡាត់ជាភាសាអារ៉ាប់មានន័យថាការគោរពបូជា ដែលជាបទបញ្ញត្តិក្នុងសាសនាអ៊ីស្លាម ។ ការគោរពបូជាគឺការព្រមចុះចូលទាំងស្រុងចំពោះ_____ ។

៣. អ្នកណាមិនបំពេញស្វ៍ឡាត់ទេ អ្នកនោះដូចអ្នក___________ព្រោះអ្នកនោះបដិសេធអល់ឡោះហ្ ។ (គួរអាន)

៤. ប្រសិនបើអល់ឡោះហ្__________ស្វ៍ឡាត់អ្នក ទង្វើល្អទាំងឡាយរបស់អ្នកក៏ដូច្នោះដែរ ។ (ព្រះសាស្តាﷺ)

៥. ប្រសិនបើអ្នកបំពេញស្វ៍ឡាត់ដឹងថា អល់ឡោះហ្ទ្រង់ព្រះរាជទានព្រះមេត្តាធម៌ព្រះអង្គមកលើរូបគេប៉ុណ្ណាខ្លះក្នុងពេលដែលគេបំពេញស្វ៍ឡាត់នោះ អ្នកនោះច្បាស់ជាមិនចង់ងើបក្បាលពី_______ ។ (អ៊ីម៉ាំអាលី صلوات الله عليه والسلام)

៦. ស្វ៍ឡាត់កម្ចាត់ភាពងងឹតពី_______ដោយសារពន្លឺនៃ_______ ។

៧. រ៉ក់អាត់ទាំង ១៧ របស់ស្វ៍ឡាត់វ៉ាយិបប្រើពេលបំពេញតែប្រមាណ_____នាទីទេ ។ មាន_____ម៉ោងក្នុងមួយថ្ងៃ ។

៨. ចូរសរសេរសេចក្ដីសំខាន់របស់ការទៀងទាត់ក្នុងការបំពេញស្វ៊ឡាត់ ។

## លំហាត់ ៩

១. ចូរបំពេញចន្លោះទទេ ។

ក. មិនអនុញ្ញាតឲ្យបំពេញស្វ៊ឡាត់លើកន្លែង ដែល_______(របស់អ្នកដទៃ) ដោយឥតបានទទួលការអនុញ្ញាត ។

ខ. កន្លែង_________ត្រូវតែ្ហហ្វៀរ ។ កន្លែងសម្រាប់____និង____អាចមិនតែ្ហហ្វៀរ កុំឲ្យតែណាយ៉ីស(نجس)រាលដាលមកដល់រាងកាយ និងសំលៀកបំពាក់របស់អ្នកស្វ៊ឡាត់ ។

គ. សម្រាប់____ បំពេញស្វ៊ឡាត់នៅឯ____ប្រសើរជាងនៅឯម៉ាស់យ៉ីដ ។

ឃ. ព្រះសាស្ដាﷺយើងមានព្រះវចនៈថា _______នឹងត្អូញប្រាប់អល់ឡោះហ្វ៍ ﷻ បើពុំមានអ្នកណាមកស្វ៊ឡាត់ទីនោះទេ ។

ង. បើនារីនិងបុរសបំពេញស្វ៊ឡាត់នៅលើកន្លែងតែមួយ គប្បីឲ្យមាន_____ ឬ _______នៅត្រង់ចន្លោះពួកគេ ។

ច. បំពេញស្វ៊ឡាត់នៅឯឆ្នេរសមុទ្រជា_______ (វ៉ាយ៉ីប/ស៊ូណាត់/ម៉ាក់រុះហ្វ/ហ្ារ៉ាំ) ។

២. វាក្យសម្ព័ន្ធខាងក្រោមនេះត្រូវឬខុស ? ចូរសរសេរ "ត" ឬ "ខ" នៅក្បែរឃ្លា ។

ក. គេអនុញ្ញាតឲ្យអ្នកបំពេញស្វ៊ឡាត់លើផ្លូវដែលមានមនុស្សដើរដាស ។___

ខ. កន្លែងស្វ៊ឡាត់មិនត្រូវមិននឹងទេ ។___

គ. បើបុរសនិងនារីបំពេញស្វ៊ឡាត់លើកន្លែងតែមួយ បុរសត្រូវដើបនិងត្រូវបំពេញ

ស្វ៍ឡាត់ក្រោយនារី ។___

ឃ. កន្លែងដាក់ថ្វាសពេលសាច់ជ្វាស់ត្រូវខ្ពស់ឬទាបបួនធ្នាប់ ជាងកន្លែងដាក់ម្រាមជើងនិងជង្គង់ ។____

ង. អ្នកនឹងបានរង្វាន់ស្មើគ្នាបើអ្នកបំពេញស្វ៍ឡាត់នៅឯ ម៉ាស់យ៉ីឌ្មុល គូហ្សាស្វ់ ឬ បៃទុល មុកក៏ដ្ជាស្វ់ ។___

៣. ចូរតម្រៀបម៉ាស់យ៉ីដ្ធខាងក្រោមនេះតាមអត្រាស្វាវ៉ាប់ ពីច្រើនទៅតិច ។

ម៉ាស់យ៉ីឌ្មុន ណាប៊ី ១)________________(ស្វាវ៉ាប់ច្រើនជាងគេ)
ម៉ាស់យ៉ីឌ្មុល គូហ្សាស្វ់ ២)________________
ម៉ាសយ៉ីដ្ធជិតខាង ៣)________________
ម៉ាស់យ៉ីឌ្មុល ហ្វារ៉ម ៤)________________

៤. ចូរលើកឡើងនូវ ៥ កន្លែងដែលម៉ាក់រុះហ្វ៍បំពេញស្វ៍ឡាត់ ។

## លំហាត់ ១០

១. ចូរគូសពាក្យដែលនៅឯប៉ែកខាងស្តាំភ្ជាប់ជាមួយអត្ថន័យរបស់វា ។

| | |
|---|---|
| ត៏ហ្វៀរ | ត្រូវសំឡេះតាមច្បាប់អ៊ីស្លាម ។ |
| មូបាស្វ់ | បរិសុទ្ធ ។ |
| ស្ងាប៊ីហ្វាស្វ់(ذبيحة) | បានមកស្របតាមច្បាប់ ។ |

២. អ្នកបាស់មិត្តរបស់អ្នកមកលេងអ្នកជាលើកដំបូង ។ ដល់ពេលស្វ៍ឡាត់ វាបានចាប់ផ្តើមបំពេញស្វ៍ឡាត់នៅឯកៀនបន្ទប់ទទួលភ្ញៀវ ។ វាបំពេញស្វ៍ឡាត់ជាមួយក្រវ៉ាត់កនិងខ្សែក ។ ក្រវ៉ាត់កសាលារបស់វាធ្វើអំពីសូត្រហើយខ្សែកវាធ្វើអំពីមាស ។ ខ្សែក្រវ៉ាត់ខោវាធ្វើអំពីស្បែកសត្វ ហើយនៅលើបន្ទះស្លាកមានសរសេរថា "Made in Cambodia" ។ តើស្វ៍ឡាត់វាត្រូវមោឃៈឬទេ ? ចូរផ្តល់មូលហេតុបីប្រការ ។

៣. ដោយផ្អែកលើឧទាហរណ៍ខាងលើនេះដដែល ប្រសិនបើអ្នកមកលេងផ្ទះអ្នកជាញាតិស្រីរបស់អ្នកឈ្មោះស៊្វបីរ៉ោះហ្វ (ពាក់ខ្សែកមាស ខ្សែក្រវ៉ាត់សាលាធ្វើអំពីសូត្រ និងខ្សែក្រវ៉ាត់ចង្កេះធ្វើអំពីស្បែកដែរ) ។ តើស៊្វឡាត់របស់នាងត្រូវមោឃៈទេ ? ហេតុអ្វី ?

៤. តើខ្សែក្រវ៉ាត់ចង្កេះធ្វើអំពីស្បែកស្ទាបីហ្វាស់(ذبيحة)ទេ (មកពីសត្វដែលត្រូវសំឡែះតាមច្បាប់អ៊ីស្លាម) ? ចូរពន្យល់ចម្លើយរបស់អ្នក ។

កំណែលើកទី ២, 06/2020